NGO
Education
Partnership

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
ផ្ទះលេខ ១១A ផ្លូវលេខ ២៤៨, សង្កាត់វាលវង់ ខណ្ឌ ៧ មករា ក្រុងភ្នំពេញ
ទូរស័ព្ទលេខៈ ០២៣ ២២៤៧៧៤ អ៊ីម៉ែលៈ info@nepcambodia.org
គេហទំព័រៈ www.nepcambodia.org

ការស្រាវជ្រាវ

# ផលប៉ះពាល់នៃចំណាយក្រៅផ្លូវការក្នុងសាលា ទៅលើការចំណាយរបស់គ្រួសារ



ទទួលការគាំទ្រពី

**អង្គការសម្ព័ន្ធសាស្ត្រាចារ្យដើម្បីអភិវឌ្ឍន៍ (PAD)**

និង

**សមាគមនារីអភិវឌ្ឍន៍ (WDA)**

ឧបត្ថម្ភដោយ

unicef

កុម្ភៈ ២០០៧

# សេចក្ដីថ្លែងអំណរគុណ

NEPសូមថ្លែងអំណរគុណដល់ក្រុមគ្រួសារទាំងអស់ដែលបានចូលរួមធ្វើបទសម្ភាសន៍នៅឯខេត្តកំពង់ចាម ដែលបានផ្ដល់ពេលវេលា និងការយកចិត្តទុកដាក់ឆ្លើយចំពោះការស្រាវជ្រាវនេះ ។ យើងខ្ញុំសូមថ្លែងអំណរគុណផង ដែរចំពោះការជួយជ្រោមជ្រែងពីសហការីស្រាវជ្រាវបួនរូបគឺ ជួប សុបិន្ត- ជា សំណាង -អ៊ុន វិបុល និងសុខ រដ្ឋា ដែលមកពីអង្គការសម្ព័ន្ធសាស្ត្រាចារ្យដើម្បីអភិវឌ្ឍន៍ និងសមាគមនារីអភិវឌ្ឍន៍ ដើម្បីជួយប្រមូលទិន្នន័យការ ស្រាវជ្រាវនេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះការខិតខំបំពេញការងារនិងការប្ដេជ្ញារបស់លោក**ខៅ សុថាត** ដែលជាអ្នកសំរបសំរួលគំរោងស្រាវជ្រាវ និងផ្ដល់ទាំងការបណ្ដុះបណ្ដាល និងការគាំទ្រចំពោះការប្រមូលនិងវិភាគ ទិន្នន័យគំរោង និងរឿងខ្លី៧ដែលចោទជាបញ្ហាចំពោះការអប់រំ ដើម្បីបញ្ចូលក្នុងរបាយការណ៍នេះ ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមរបស់ **ជុលៀត ស៊ី អ៊ុយ** អ្នកស្ម័គ្រចិត្តមកពីអង្គការ VSO ចំពោះការជួយសរសេរបកស្រាយទិន្នន័យ និងសរសេរសេចក្ដីព្រាងរបាយការណ៍ស្រាវជ្រាវដំបូង ។

យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះការចូលរួមមិនអាចកាត់ថ្លៃបានរបស់ **រូនីន ម៉ាឃ្យូ** ដែលជា ទីប្រឹក្សាគ្រប់គ្រងសំរាប់ NEP តាមរយៈការបណ្ដុះបណ្ដាល និងប្រមូលទិន្នន័យ ក៏ដូចជាជំនាញសរសេរ និងកែតម្រូវដ៏ប៉ិនប្រសព្វដែលជួយអោយមានរបាយការណ៍ស្រាវជ្រាវដ៏ពេញលេញមួយនេះ ។

លើសពីនេះទៅទៀតយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក **សេខ ហុខ** ដែលជា នាយកប្រតិបត្តិ NEP ចំពោះការរួមចំណែកចំនេះដឹង និងជំនាញក្នុងការធ្វើគំរោង និងវិភាគទិន្នន័យរបស់គំរោង ។ យើងខ្ញុំសូមបង្ហាញនូវការកោតសរសើរផងដែរចំពោះ **ផាន់ ចាន់ហឿន** និង **ឌី តារាភ្នួន** ចំពោះការបកប្រែ របាយការណ៍នេះជាភាសាខ្មែរ ។

ជាចុងបញ្ចប់យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការជួយឧបត្ថមទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេសពីសំណាក់អង្គការ UNICEF និង អង្គការសេវាស្ម័គ្រចិត្តបរទេស ចំពោះការគាំទ្រដល់គំរោងនេះ ។

# របាយការណ៍សង្ខេប

ដោយមានការធ្លាក់ចុះស្ថិតិការអប់រំនៅកម្ពុជា ដែលបង្ហាញអំពីអត្រាចូលរៀន និងអត្រាគង់វង់របស់សិស្សថ្នាក់បឋមសិក្សា ការស្រាវជ្រាវនេះមានបំណងស្វែងយល់ពីទំនាក់ទំនងកើតឡើងរវាងនិន្នាការធ្លាក់ចុះនេះ និងលទ្ធភាពរបស់ឪពុកម្តាយក្នុងការចំណាយក្រៅផ្លូវការនៅតែកើតមាននៅសាលារដ្ឋនានាដែរឬទេ។ ការសិក្សានេះ ធ្វើឡើងនៅខេត្តកំពង់ចាមហើយមានបំណងស្វែងយល់ទាំងចំនួនទឹកប្រាក់ចំណាយក្រៅផ្លូវការក្នុងសាលាដែលចំណាយដោយឪពុកម្តាយក្នុងការបញ្ជូនកូនទៅរៀន ក៏ដូចជាផលប៉ះពាល់ផ្សេងៗលើគ្រួសារ ចំពោះការរក្សាកូនអោយទៅរៀន។

គ្រួសារចំនួន១០០ត្រូវបានសម្ភាសន៍នៅក្នុងស្រុកចំនួន១៦ ក្នុងខេត្តកំពង់ចាម។ ជាមធ្យមគ្រួសារនីមួយៗមានកូន២ ឬ ៣នាក់បានចូលរៀន។ ថ្លៃចំណាយក្រៅផ្លូវការទៅអោយសាលាមាន៤ផ្នែក សំខាន់ៗគឺៈ ចំណាយដើមឆ្នាំ ថ្លៃសាលា ចំណាយប្រចាំថ្ងៃ និងចំណាយផ្សេងៗ។

ការសិក្សានេះបានរកឃើញថាឪពុកម្តាយចំណាយពី ៧៦.០០០ ទៅ ៨៨.៥០០ រៀល ក្នុងមួយឆ្នាំ ទៅលើការចំណាយដើមឆ្នាំ រួមមានការចំណាយលើ ឯកសណ្ឋានសាលា សម្ភារៈសិក្សា និងការចុះឈ្មោះចូលរៀន។ ឯថ្លៃសាលា រួមមានៈ ថ្លៃគ្រូបង្រៀន រៀនគួរ ក្រដាសមេរៀន និងក្រដាសប្រលង ដែលជាចំណាយខ្ពស់ទីពីរ ដែលជាមធ្យមចំណាយអស់ ២០៩.៥០០រៀល សំរាប់កុមារម្នាក់ ក្នុងរយៈពេលមួយឆ្នាំ។ ក្នុងចំណោមថ្លៃសាលា ចំណាយរៀនគួរខ្ពស់ជាងគេបង្អស់។ ចំណាយប្រចាំថ្ងៃរួមមានៈ អាហារនិងចំណី បង្អែត ជាចំណែកធំបំផុតលើចំណាយលើការអប់រំ អស់ប្រមាណពី១៦៩.០០០ ទៅ ២៨៩.០០០ រៀល ជារៀងរាល់ឆ្នាំ។ ហើយជាចុងបញ្ចប់ក្រុមគ្រួសារទាំងនោះបានអោយដឹងថាពួកគេចំណាយពី ១៤.២០០ ទៅ ២៣.៤០០រៀលទៀត លើការចំណាយបន្ថែមពេញមួយឆ្នាំចំពោះ សម្ភារៈសិក្សា និង សម្ភារៈថ្នាក់រៀន ជួសជុលកង់/ម៉ូតូ អំណោយគ្រូ ពិធីផ្សេងៗ និងការប្រគល់សៀវភៅតាមដានពិន្ទុសិស្សពីគ្រូទៅឪពុកម្តាយ។

ជារួម ឪពុកម្តាយ និងសិស្សដែលសម្ភាសន៍ បានឱ្យដឹងថាពួកគេចំណាយជាមធ្យមពី ៤៤០.១០០ រៀល (១១០ ដុល្លាអាមេរិច) ទៅ ៦១៣.៩០០ រៀល (១៥១ដុល្លាអាមេរិច) ក្នុងការបញ្ជូនកូនម្នាក់ទៅរៀន សំរាប់មួយឆ្នាំ។ ចំនួននេះស្មើនឹង១០% ទៅ១៩%នៃចំណូលគ្រួសារសរុបប្រចាំឆ្នាំ ដើម្បីបញ្ជូនកូនម្នាក់ទៅរៀន ហើយចំណាយទាំងនេះនឹងកើនឡើងស្របគ្នា ប្រសិនបើពួកគេបញ្ជូនកូន២រឺច្រើននាក់ទៅរៀនសាលារដ្ឋ។

បន្ថែមលើការគណនាចំណាយក្រៅផ្លូវការក្នុងសាលាដោយឪពុកម្តាយ។ ការសិក្សានេះក៏មានបំណងផ្តោតទៅលើឥទ្ធិពលដល់គ្រួសារចំពោះការរក្សាកូនឱ្យនៅរៀន។ ជាពិសេសមូលហេតុដែលធ្វើអោយកុមារបោះបង់ចោលសាលា ក៏ដូចជាសកម្មភាពដែលកុមារចូលរៀន និងមិនចូលរៀន ដោយនៅក្រៅសាលា នាម៉ោងរៀន ត្រូវបានរក

ឃើញ។ វាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលឡើយ មូលហេតុចំបងដែលធ្វើអោយកុមារឈប់រៀនគឺឪពុកម្តាយគ្មានលទ្ធភាពចំណាយលើថ្លៃសាលាបន្តទៀត។ មូលហេតុផ្សេងៗទៀតគឺជាប់ពាក់ព័ន្ធទៅនឹងគុណភាពសាលា រឺក៏គ្រួសារត្រូវការកំលាំងពលកម្មកូន។ ពតិមានដែលប្រមូលបានទាំងនេះ ត្រូវបានបញ្ចូលក្នុងរបាយការណ៍ ក្នុងនោះរួមមានការវិភាគទិន្នន័យជាលេខ លើថ្លៃសាលា និងការបង្ហាញអំពីករណីរឿងខ្លីក្នុងរបាយការណ៍ នេះផងដែរ ។

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីធ្វើការបំភ្លឺពីតថភាពប្រឈមដោយគ្រួសារទាំងឡាយក្នុងប្រទេសកម្ពុជាចំពោះ “ការចំណាយក្រៅផ្លូវការក្នុងសាលា” ។ ធ្វើដូច្នេះសង្ឃឹមថាលទ្ធផលស្រាវជ្រាវអាចប្រើជាឯកសារយោងសំរាប់ការពិភាក្សាលើគោលនយោបាយបន្ថែមនានា អំពីការបង្កើនការចូលរៀនដោយលុបបំបាត់ថ្លៃសាលាផ្សេងៗ ឱ្យបានទាំងអស់គ្នា។

# ជំពូក១

# បញ្ហា និងទំហំនៃបញ្ហា

## ១.១ សេចក្តីផ្តើម

ការអប់រំគឺជាកេរ្តិ៍មរតកដ៏វិសេសវិសាលបំផុតដែលឪពុកម្តាយអាចផ្តល់អោយកូន។ ឪពុកម្តាយមួយចំនួនធំស្ម័គ្រចិត្តធ្វើការវិនិយោគធនធានដ៏កំររបស់គាត់ដោយមានការរំពឹងទុករយៈពេលវែង ថានឹងសំរេចបាននាពេលណាមួយ។ ការអប់រំគឺជាទ្រព្យដ៏មានតំលៃដែលមិនចេះសាបសូន្យ ប៉ុន្តែការយល់ឃើញរបស់ឪពុកម្តាយ ចំពោះតំលៃនៃការអប់រំ តែងត្រូវបានដាក់កំហិតដោយលក្ខខ័ណ្ឌសេដ្ឋកិច្ច និងការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ។ ឪពុកម្តាយ ដែលមានការចេះដឹងជ្រៅជ្រះ និងជីវភាពធូរធារ មានបំណងបញ្ជូនកូនទៅសាលាល្អៗ និងចង់អោយកូនចៅរបស់ពួកគេបញ្ចប់ការសិក្សាជាមួយនឹងការជឿជាក់ថា គុណភាពនៃការអប់រំគឺជាស្ពានចម្លងទៅរកគុណភាពនៃជីវិត។ ម្យ៉ាងវិញទៀត ឪពុកម្តាយដែលមានជីវភាពលំបាកតែងតែរំពឹងថា កូនរបស់គាត់ ដែលកំពុងតែមានអាយុត្រូវចូលរៀនគួរតែធ្វើការងារ ដើម្បីជួយរកប្រាក់ចំណូលបន្ថែមបន្តិចបន្តួចដល់គ្រួសារ។ ឪពុកម្តាយទាំងនេះអាចឱ្យតំលៃផ្សេងចំពោះអត្ថប្រយោជន៏រយៈពេលវែងនៃការអប់រំ និងទាមទារតំរូវការភ្លាមៗសំរាប់ជីភាពគ្រួសារគាត់សំខាន់ជាងការអប់រំ។ តថភាពនេះតែងធ្វើអោយអត្រាអនក្ខរកម្ម និងអត្រាឆាប់បោះបង់ចោលការសិក្សាខ្ពស់ក្នុងចំណោមកុមារក្រីក្រនិងទីទាល់ក្រ។

ចំពោះប្រទេសទាំងឡាយដែលប្រជាជនភាគច្រើនជាជនក្រីក្រ អនក្ខរកម្ម ជាមូលហេតុមួយទៀតធ្វើឱ្យមានការខ្វះខាតថែមទៀត និងរារាំងសុខុមាលភាពសេដ្ឋកិច្ច ការអភិវឌ្ឍន៏នៃមនុស្ស និងកូនចៅរបស់ពួកគេ ហើយនៅទីបំផុតជាបន្ទុកដល់សង្គមជាតិ។ ដូចដែលមានថ្លែងនៅក្នុងរបាយការណ៍របស់សាលាឆ្នាំ២០០៥ “ត្រូវធ្វើអោយប្រសើរឡើង”។

ថ្វីត្បិតតែការសន្យាច្បាស់លាស់មួយ បានធ្វើឡើងដោយអ្នកដឹកនាំលើពិភពលោក ដើម្បីផ្តល់ការអប់រំសំរាប់ទាំងអស់គ្នានៅឆ្នាំ២០១៥ ក៏ដោយក៏មនុស្សរាប់លាននាក់នៅតែមិនបានចូលរៀននៅសាលា រឺមជ្ឈមណ្ឌលអក្ខរកម្មមនុស្សពេញវ័យនៅឡើយទេ។ នៅក្នុងតំបន់អាស៊ីប៉ាស៊ីភិចមានការទទូចចង់បានយ៉ាងខ្លាំងខ្លាពីតំរូវការនៃការសិក្សាថ្នាក់មត្តេយ្យ និង ការអប់រំសំរាប់ម្តាយ ដែលកិច្ចការនេះ មិនត្រឹមតែ រួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍន៏ការយល់ដឹងរបស់កុមារប៉ុណ្ណោះទេ តែក៏ជាការបង្កើនឱកាសសំរាប់កូនច្បង (ជាពិសេសកូនស្រី) និងម្តាយអោយទទួលបានការអប់រំ ដោយពុំចាំបាច់តំរូវឱ្យម្តាយត្រូវចំណាយពេលសំរាប់ការថែទាំកូនតូចៗទៀតទេ។ យោងតាម របាយការណ៏ (ត្រូវធ្វើអោយប្រសើរឡើង ឆ្នាំ២០០៥ ទំព័រទី ១៦)។

នៅក្នុងប្រទេសកម្ពុជា នៅពេលដែលអត្រារៀនចប់ថ្នាក់បឋមសិក្សាត្រឹមតែ ៥១ភាគរយ ចំពោះកុមារា និង ៣៣,៩ភាគរយ ចំពោះកុមារី វាជាមូលហេតុសំខាន់មួយដែលគួរអោយព្រួយបារម្ភ។ យោងតាម (http://www.usaid.gov/pubs/cbj2003/ane/kh/) ការធ្លាក់ចុះថ្មីៗចំពោះអត្រាចុះឈ្មោះចូលរៀន និងអត្រាសិស្សនៅរៀនដល់ថ្នាក់ទី៦ ចង្អុលបង្ហាញថាអក្ខរកម្មមនុស្សពេញវ័យអាចឈ្មោះទៅរកការធ្លាក់ចុះផងដែរ។ (NSDP របាយការណ៍នៃការរីកចំរើនប្រចាំឆ្នាំ ២០០៦)។ ការសិក្សានេះបង្ហាញថាស្ត្រីប្រហែល៤៣% និងបុរស ២០% ដែលមានអាយុ២៥ឆ្នាំ ឡើងទៅ មិនបានរៀនចប់ថ្នាក់ដំបូង ហើយស្ត្រីមានត្រឹមតែ ០,៤% និងបុរស១,៨% ប៉ុណ្ណោះដែលបានរៀនចប់ថ្នាក់មធ្យមសិក្សា យោងតាម (CSES ២០០៤)។

បញ្ហាប្រឈមចំពោះវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាគឺមានទំហំធំធេងណាស់។ ទោះបីជារាជរដ្ឋាភិបាលបានខិតខំធ្វើការដើម្បីបង្កើតនូវផែនការអប់រំជាតិដែលជួយអ្នកក្រពិតប្រាកដមួយ តាមរយៈ គោលនយោបាយជាតិអប់រំសំរាប់ទាំងអស់គ្នា ២០០៣-២០១៥ ក៏ដោយ ក៏ការអនុវត្តគំរោងនេះនៅតែធ្លាក់ចុះយ៉ាងខ្លាំង គឺទាបឆ្ងាយជាងទិសដៅដែលបានកំនត់។ គោលដៅមួយក្នុងចំណោមគោលដៅដែលបានកំនត់គោលនយោបាយអប់រំសំរាប់ទាំងអស់គ្នា(EFA) និងក្រោយមក បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអប់រំ (ESP) ២០០៦-២០១០ ដោយបានដាក់ទិសលុបបំបាត់ការចំណាយ ក្រៅផ្លូវការនានាពីថ្នាក់ទី១-៩ ទូទាំងប្រទេសនៅចុងឆ្នាំ២០០៨។ ជាភ័ព្វមិនល្អការស្រាវជ្រាវនេះ និងការស្រាវ ជ្រាវដទៃទៀតបង្ហាញថា៤ឆ្នាំនៅក្នុងគំរោងរយះពេល១២ឆ្នាំរបស់EFA សាលានៅក្នុងប្រទេសកម្ពុជា នៅតែមានតំរូវការវិភាគទានផ្នែកហិរញ្ញវត្ថុពីកុមារ ហើយថ្លៃចំណាយទាំងនេះជាក់ស្តែងមានការកើនឡើង។ ពេលដែល វិភាគទានផ្នែកហិរញ្ញវត្ថុទាំងនេះមានការខុសៗគ្នាពីសាលាមួយ ទៅសាលាមួយទៀត ជាការពិតកុមារដែលគានលទ្ធភាពបង់ “ចំណាយក្រៅផ្លូវការក្នុងសាលា” មានហានិភ័យខ្ពស់ចំពោះការប្រលងធ្លាក់ រឺឆាប់បោះបង់ការសិក្សា។ (Roberts, ២០០៦)

ក្នុងការធ្វើកាស្រាវជ្រាវនេះយើងបានយកចិត្តទុកដាក់ផងដែរទៅលើបញ្ហានានាដែលកំពុងប្រឈមមុខគ្រូបង្រៀនដែលមានភក្តីភាពរាប់ពាន់នាក់ក្នុងប្រទេសកម្ពុជាដែលខិតខំធ្វើការដើម្បីផ្តល់ការអប់រំតែងស្ថិតនៅក្រោមស្ថានភាពលំបាកបំផុត។ ប្រាក់បៀវត្សរ៍ដែលចំណាយទៅអោយគ្រូនៅប្រទេសកម្ពុជាគឺទាបបំផុត ហើយនេះគ្រាន់តែជាផ្នែកមួយដែលការសិក្សានេះបង្ហាញតែប៉ុណ្ណោះ យ៉ាងណាក៏ដោយក៏ពុំមានបំណងស្តីបន្ទោសដល់គ្រូបង្រៀនចំពោះការប្រមូល”ចំណាយក្រៅផ្លូវការ” នេះឡើយ នៅក្នុងប្រព័ន្ធអប់រំមួយដែលមិនត្រឹមតែអនុគ្រោះការអនុវត្តបែបនេះ ប៉ុន្តែពឹងផ្អែកលើវាផងដែរសំរាប់បន្តដំណើរការទៅមុខទៀត ។

## ១.២ ប្រវត្តិ

ចាប់តាំងពីឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយនានាបានអនុវត្តដំនើរការកំណែទំរង់គោលនយោបាយអប់រំ ដោយមានបំណងផ្តល់សេវាអប់រំដល់កុមារទាំង

អស់នៅកម្ពុជា។ តាមរយៈការផ្តួចផ្តើមការអប់រំសំរាប់ទាំងអស់គ្នាជាអន្តរជាតិ រដ្ឋាភិបាលបានអភិវឌ្ឍគំរោងការអប់រំសំរាប់ទាំងអស់គ្នាថ្នាក់ជាតិ ដែលមានរយៈពេល១២ឆ្នាំរបស់ខ្លួន ដែលជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍បន្ថែមនៃផែនការយុទ្ធសាស្ត្រអប់រំ៥ឆ្នាំ (ESP) និងកម្មវិធីគាំទ្រវិស័យអប់រំមួយឆ្នាំរំកិល (ESSP)។

កម្មវិធីសកម្មភាពអាទិភាព(PAP) ដែលស្ថិតនៅក្រោម ESSP ដែលជាយន្តការហិរញ្ញវត្ថុសំរាប់កម្មវិធីអាទិភាពចំណាយចរន្តត្រូវបានបង្កើតឡើងដើម្បីជាស្ពានសំរាប់នាំមូលនិធិអប់រំសំរាប់រដ្ឋាភិបាល និងដើម្បីធានានូវមូលនិធិជាមូលដ្ឋានចាំបាច់សំរាប់ការប្រតិបត្តិតាមសាលារៀន។ មូលនិធិអប់រំនេះមានបំណងផ្តល់ការអប់រំថ្នាក់មូលដ្ឋានដល់កុមារ ដោយមិនគិតថ្លៃរហូតដល់ថ្នាក់ទី៩។ ថ្វីបើរដ្ឋាភិបាលបានគាំទ្រលើវិស័យអប់រំក៏ដោយ ក៏ឪពុកម្តាយនៅ តែចំណាយដើម្បីអោយកូនបានរៀនសូត្រ។ ដោយសារថវិការដ្ឋត្រូវបានចាត់ទុកជាផ្លូវការ ថាគ្រប់គ្រាន់លើចំណាយទាំងស្រុងដើម្បីអោយកុមារកម្ពុជាចូលរៀនដោយមិនបង់ថ្លៃវិភាគនានា ដូចនេះការចមណាយរបស់ឪពុកម្តាយ ទៅលើការបញ្ជូនកូនទៅសាលារៀន ចាត់ទុកថាជា" ចំណាយក្រៅផ្លូវការក្នុងសាលា"។ ថ្លៃចំណាយក្រៅផ្លូវការទាំងនេះ វាបំពេញបន្ថែមដល់ប្រាក់បៀវត្សរ៍ដ៏តិចតួចរបស់គ្រូបង្រៀន ដែលឧបត្ថម្ភដោយរដ្ឋ ក៏ដូចជាការបំពេញបន្ថែមដល់ចំណាយប្រតិបត្តិការណ៍ខ្លះដែលមូលនិធិរដ្ឋមិនទាន់មានលក្ខណៈគ្រប់គ្រាន់។

ការស្រាវជ្រាវនេះធ្វើឡើងដើម្បីឆ្លើយតប ទៅនឹងកង្វល់ដែលបានលើកឡើងនៅឯកិច្ចប្រជុំនានាជាមួយរាជរដ្ឋាភិបាល និងម្ចាស់ជំនួយនានា អំពីការផ្តល់មូនិធិ PAP មិនទាន់ពេល ដែលជាបញ្ហាចំបងរយៈពេលជាច្រើនឆ្នាំមកហើយ។ លើសពីនេះទៅទៀត បញ្ហាប្រាក់បៀវត្សរ៍គ្រូបង្រៀនទាប រួមទាំងស្ថិតិរបស់រដ្ឋាភិបាលថ្មីៗនេះបង្ហាញពីការធ្លាក់ចុះការចុះឈ្មោះចូលរៀន និងអត្រាគង់វង់នៃសិស្សរៀនថ្នាក់បឋមសិក្សា ដែលត្រូវបានចោទជាសំនួរអំពីការប្តេជ្ញារបស់រដ្ឋាភិបាលទៅលើហិរញ្ញវត្ថុសំរាប់អ្នកក្រ។

សេចក្តីរំពឹងពីការស្រាវជ្រាវនេះគឺផ្តល់ជាពន្លឺខ្លះចំពោះស្ថានភាពបច្ចុប្បន្នដោយផ្អែកលើ “ការចំណាយក្រៅផ្លូវការក្នុងសាលា” ហើយការលទ្ធផលនៃការស្រាវជ្រាវនេះ ជាឯកសារយោង ជាភស្តុតាងសម្រាប់ការពង្រឹងគោលនយោបាយតទៅទៀត ដែលនឹងធានាការចូលរៀនដោយសមភាពសំរាប់កុមារក្នុងប្រទេសកម្ពុជា ដោយពុំគិតដល់លទ្ធភាពចំណាយរបស់ពួកគេ។

## ១.៣ គោលទ្រឹស្តី

### ១.៣.១ រំលឹកឡើងវិញនូវអត្ថបទ និងការសិក្សាដែលពាក់ព័ន្ធ

ការអប់រំជីវតួជាមូលដ្ឋានគ្រឹះសំរាប់ជីវិតដ៏ត្រចះត្រចង់។ វាបានបង្កើនការរីកដុះដាលយ៉ាងខ្លាំង ក្នុងការបង្កើតឱកាសការងារ និងជាសក្តានុពលក្នុងការរកប្រាក់ចំណូល បើតាមសំដីរបស់ Rivera (២០០៧)។ ភាពជោគជ័យនៅថ្នាក់ឧត្តមសិក្សាគឺអាស្រ័យទៅលើគុណភាពអប់រំថ្នាក់មូលដ្ឋាន។ សមត្ថភាពអាន និងសរសេរគឺស្ថិតក្នុងមូលដ្ឋានជីវិតដែលមនុស្សគ្រប់រូបត្រូវតែមាន។ បើគ្មានការអប់រំទេ អនាគតរបស់កុមារនឹងមិនប្រាកដប្រជា ហើយ

គ្មានន័យ។ ការប្រកាសជាសកលអំពីការអប់រំសំរាប់ទាំងអស់គ្នា បានអនុម័តនៅ Jomtiem ប្រទេសថៃ ក្នុងខែមិនា ឆ្នាំ១៩៩០ មានបំណងធានាថាមនុស្សគ្រប់រូប កុមារ យុវជន មនុស្សពេញវ័យនឹងអាចទទួលប្រយោជន៍ ទទួលបាន ឱកាសអប់រំដើម្បីបំពេញតំរូវការមូលដ្ឋានរបស់ពួកគេ។ ១០ឆ្នាំក្រោយមកនៅ Dakar Senegal ឯវេទិកាអប់រំ ពិភពលោក (២៦-២៨ ខែមេសា ឆ្នាំ២000) គំរោងសកម្មភាពDakar ត្រូវបានបង្កើតឡើង។ អ្នកចូលរួមក្នុង វេទិការនេះ បានបញ្ជាក់ពីជំហររបស់ខ្លួនឡើងវិញ ចំពោះការប្រកាសជាសកលលោក អំពីការអប់រំសំរាប់ទាំង អស់គ្នា ជាថ្មីម្តងទៀត និងប្តេជ្ញចិត្ត ដើម្បីសំរេចបានគោលដៅការអប់រំសំរាប់ទាំងអស់គ្នា ដែលកំនត់នៅឆ្នាំ ២០១៥ ដោយបានទទួលស្គាល់គោលដៅទាំងអស់នេះ ដោយពង្រឹង ឬអភិវឌ្ឍផែនការជាតិ នាឆ្នាំ២00២។

ក្រៅពីមហិច្ឆតាផែនការជាសកលអប់រំសំរាប់ទាំងអស់គ្នា កុមារប្រហែល ១១៣លាននាក់ទូទាំងពិភព លោក មិនទាន់ចូលរៀននៅឡើយទេនៅឆ្នាំ២00៣ ដោយយោងទៅតាមរបាយការណ៍កម្មវិធីអភិវឌ្ឍអង្គការ សហប្រជាជាតិ តាមសំដីរបស់ Hillman និង Jenkner (២00៤)។ លើសពីនេះទៅទៀត ពេលដែលការអប់រំ មូលដ្ឋាន (ថ្នាក់ទី១-៦) មានបំណងឱ្យរៀនដោយឥតគិតថ្លៃនៅប្រទេសជាច្រើនលើពិភពលោក តែកុមារជាច្រើន មកពីគ្រួសារទីទ័លក្រ នៅតែមិនអាចចូលរៀនបាននៅក្នុងប្រទេសជាច្រើន រួមទាំងប្រទេសកម្ពុជាផងដែរ។

តាមគំរោងសកម្មភាព Dakar រាជរដ្ឋាភិបាលកម្ពុជា បានធ្វើផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា២00៣ -២០១៥។ ក្រោយមក ផែនការយុទ្ធសាស្រ្តអប់រំ(ESP) ដែលកំនត់មាគ៌ាដ៏អស្ចារ្យសំរាប់ការទទួល ស្គាល់ការអប់រំ ជាមូលដ្ឋាន។ ការសំរេចចិត្តបានកំណត់ថានៅក្នុងប្រទេសកម្ពុជាការអប់រំជាមូលដ្ឋាន គួរតែរាប់ បញ្ចូលការអប់រំ កំរិតបឋមសិក្សា ដែលមានរយះពេល៦ឆ្នាំ និងកំរិតអនុវិទ្យាល័យដែលមានរយៈពេល៣ឆ្នាំថែមទៀត។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា បានកំនត់ក្នុងយុទ្ធសាស្រ្តចតុកោណសំរាប់ការអភិវឌ្ឍន៍ បានដាក់បញ្ចូលគុណភាពអប់រំ គឺជាសមាសភាពសំខាន់នៃសមាសភាពទាំងបួន ដោយឱ្យចំណេះដឹងថា ការកសាង សមត្ថភាព និងអភិវឌ្ឍមនុស្ស។ ការគាំទ្រការអភិវឌ្ឍន៍ធនធានមនុស្ស រាជរដ្ឋាភិបាលកម្ពុជាកំពុងទទួលស្គាល់ ការទទួលខុសត្រូវរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹង "តំរូវការពលកម្មទីផ្សារក្នុងលក្ខខ័ណ្ឌជាសហគ្រិន មានការ ឆ្នៃប្រឌិត ការទទួលខុសត្រូវ វិន័យ ចរិយាធមិ គុណធមិ ក្រមសីលធមិខ្ពស់ និងភាពស្មោះត្រង់នៅក្នុងការ ខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បី លើកទឹកចិត្តអោយមានការអភិវឌ្ឍន៍" (ESP ឆ្នាំ២00៦-២០១០ ទំព័រទី៨)។

ជាភ័ព្វមិនល្អ ពេលដែលការអប់រំត្រូវបានដាក់ជាគោលដៅអភិវឌ្ឍជាអទិភាពមួយ នៅក្នុងឆ្នាំ ២00៤ ក្នុងចំណោមយុវជនកម្ពុជាដែលមានអាយុ (២០-២៩ឆ្នាំ) ក្នុងទីផ្សារពលកម្ម មានតែ១៧ភាគរយប៉ុណ្ណោះ បាន រៀនចប់ការអប់រំថ្នាក់មធ្យមសិក្សា (ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជាឆ្នាំ២00៤)។ បញ្ហាធំ២ពីរក្នុងចំណោម បញ្ហាជាច្រើនចំពោះការអប់រំក្នុងប្រទេសកម្ពុជាគឺការធ្លាក់ចុះអត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា និងអត្រា

ទាបរបស់សិស្សដែលបន្តរៀនដល់ថ្នាក់ទី ១-៦ និង ១-៩។ ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ ដំណើរការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០០៦ " និន្នាការដែលគេមិនចង់បានទាំងនេះ អាចសន្មតបានពីការរៀនត្រួតថ្នាក់ និងការបោះបង់ចោលសាលានៅកំរិតទាំងពីរនេះមានកំរិតខ្ពស់។" ថ្វីបើការធ្វើផែនការ និងការអភិវឌ្ឍន៍ប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជាអស់រយះពេលជាច្រើនឆ្នាំក៏ដោយ ក៏អត្រាចុះឈ្មោះចូលរៀន និងអត្រាគង់វង់នៅកំរិតបឋមសិក្សានៅតែមានការធ្លាក់ចុះ។ តើគួរធ្វើដូចម្តេចចំពោះនិន្នាការដែលធ្លាក់ចុះនេះ?

នៅក្នុងការសិក្សាលើចំណាយឯកជនចំពោះការអប់រំនៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើក្នុងឆ្នាំ១៩៩៩ Bray បានណែនាំថា "កំរិតនៃការបោះបង់ចោលសាលានៅថ្នាក់បឋមសិក្សាក្នុងប្រទេសកម្ពុជាបានបង្ហាញថានឹងមានការកើនឡើង។ ការចំណាយហាក់បីដូចជាកត្តាយ៉ាងសំខាន់មួយសំរាប់ក្រុមគ្រួសារជាច្រើនពេលដែលពួកគាត់ធ្វើការសំរេចចិត្តថាតើគួបញ្ឈប់កូនពីសាលារឺអត់។" (Bray ឆ្នាំ១៩៩៩ ទំព័រទី៨0) ដោយយោងទៅតាម Bray ការចំណាយរបស់ឳពុកម្តាយសំរាប់ការអប់រំថ្នាក់បឋមសិក្សាមានចន្លោះពី ៥0.000រៀល ទៅ ២៥៥.000 រៀលក្នុងកូនម្នាក់ក្នុងមួយឆ្នាំសំរាប់ថ្នាក់ទី១ កើនឡើងទៅដល់ពី ២២៤.000 ទៅ ៥0៧.000រៀល សំរាប់ថ្នាក់ទី៦ អាស្រ័យទៅតាមទីកន្លែងរស់នៅ។ ការចំណាយនេះស្ថិតនៅក្នុងចន្លោះណាមួយចាប់ពី ៥,៣% ទៅ ២0,៤% នៃចំណូលប្រចាំឆ្នាំ ក្នុងគ្រួសារសំរាប់កូនម្នាក់។ (Bray ឆ្នាំ១៩៩៩ ទំព័រទី ៧៦-៧៧)។

យោងតាមទិន្នន័យប្រជាសាស្ត្រ លើគ្រួសារក្នុងប្រទេសកម្ពុជា ឃើញថាជាទូទៅគ្រួសាររស់នៅតំបន់ទីប្រជុំជនមានកូន៥,៧នាក់ ចំណែកគ្រួសាររស់នៅតាមតំបន់ជនបទមានកូន៥.៣នាក់។ (http://www.moc.gov.kh/national_data_resource) ចំណាយក្នុងការបញ្ជូនកូនទាំង៥ ឱ្យទៅរៀនហួសពីសមត្ថភាពចំណាយរបស់គ្រួសារ យ៉ាងច្រើនលើសលប់។ បើមើលឧទាហរណ៍គ្រួសារមួយមានកូន៥នាក់ដែលមានអាយុចន្លោះពី៦ ទៅ១៥ឆ្នាំ ចំណាយសំរាប់ការអប់រំកូនទាំងប្រាំ តាមទ្រឹស្តីការចំណាយប្រើប្រាស់លើសពី ៦0-៧៥% នៃចំនូលក្នុងគ្រួសារសរុប។ នេះបញ្ជាក់ច្បាស់ថា ក្នុងកាលៈទេសៈនេះការសំរេចចិត្តដ៏ពិបាក នឹងត្រូវតែធ្វើឡើង ដោយគិតថាកូនមួយណាអាចនៅរៀនបន្ត និងកូនមួយណាដែលត្រូវតែឈប់រៀនដើម្បីជួយផ្គត់ផ្គង់ដល់ការ ជោគជ័យសំរាប់អនាគតរបស់បងប្អូន ពួកគេ។

ការស្រាវជ្រាវជាច្រើនបានចង្អុលបង្ហាញការពិតថា នៅក្នុងក្រុមគ្រួសារកម្ពុជាជាច្រើន សំរេចចិត្តបញ្ជូនកូនប្រុសទៅសាលាច្រើនជាងកូនស្រី ដែលភាគច្រើន និងជាទូទៅដោយការកើនឡើងនូវកង្វះខាតសេដ្ឋកិច្ច។ យោងទៅតាមរបាយការណ៍សាលា ពីប្រទេសកំពុងអភិវឌ្ឍចំនួន១៤ នៅតំបន់អាស៊ី-ប៉ាស៊ីភិច "**ត្រូវធ្វើអោយប្រសើរឡើង**" ប្រទេសកម្ពុជាបានធ្លាក់ចំណាត់ថ្នាក់ចំពោះសមធិមយេនឌ័រដោយសារចំនួនភាគច្រើននៃកុមារដែលបោះបង់ចោលសាលានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាជាកុមារី ហើយក្នុងចំនោមអនក្ខរជន មនុស្សពេញវ័យ ១0នាក់ មាន៧នាក់ជាស្ត្រី"។(ASPBAE ២00៥)

ការប្រឈមចំពោះមុខ និន្នាការដែលគេមិនចង់បាននៅក្នុងប្រទេសកម្ពុជានេះ NEP ក្នុងភាពជាដៃគូជាមួយអង្គការសមាជិកចំនួនពីរ (អង្គការសម្ព័ន្ធសាស្ត្រាចារ្យដើម្បីអភិវឌ្ឍ និងសមាគមនារីអភិវឌ្ឍ) បានសំរេចចិត្តធ្វើគំរោងស្រាវជ្រាវ ថ្នាក់សហគមន៍ដើម្បីរកឱ្យឃើញថា ការចំណាយរបស់ឪពុកម្តាយចំពោះការអប់រំ គឺជាកត្តាមួយដែលជំរុញអោយមានការធ្លាក់ចុះអត្រាចូលរៀន និងអត្រាគង់វង់ នៅថ្នាក់បឋមសិក្សានាបច្ចុប្បន្ន។

## ១.៣.២ បញ្ហានៃការស្រាវជ្រាវ

យោងតាមស្ថិតិរបស់រាជរដ្ឋាភិបាលកម្ពុជាថ្មីៗនេះ បានបង្ហាញការធ្លាក់ចុះអត្រាចូលរៀនថ្នាក់បឋមសិក្សា និងអត្រាគង់វង់នៅថ្នាក់ទី៦ និងទី៩ គោលបំណងនៃការស្រាវជ្រាវនេះគឺកំនត់ថាតើ មានទំនាក់ទំនង រវាងនិន្នាការធ្លាក់ចុះនៃអត្រាចូលរៀន និងអត្រាគង់វង់ ទៅនឹងលទ្ធភាពរបស់ឪពុកម្តាយក្នុងការចំណាយក្រៅផ្លូវការ បន្តមាននៅក្នុងសាលារដ្ឋនានាដែរឺទេ? ដូច្នេះហើយការស្រាវជ្រាវនេះគឺដើម្បីស្វែងយល់ពី ចំនួនទឹកប្រាក់ក្រៅផ្លូវការដែលឪពុកម្តាយត្រូវចំណាយក្នុងការបញ្ជូនកូនម្នាក់ទៅសាលា ព្រមទាំងផលប៉ះពាល់ដល់ក្រុមគ្រួសារក្នុងការរក្សាកូនឱ្យនៅបន្តរៀនសូត្រ រឺក៏បញ្ឈប់។

ជាពិសេស វាតំរូវអោយអ្នកផ្តល់ពិតមាន ឆ្លើយនូវសំនួរដូចខាងក្រោមៈ

១, តើអ្វីទៅជាចំលើយរបស់ឪពុកម្តាយដែលឆ្លើយតបក្នុងលក្ខខ័ណ្ឌនៃៈ

- ១,១ ទំហំគ្រួសារ
- ១,២ ចំនួនកូន
- ១,៣ តើកូនៗរស់នៅឯណា
- ១,៤ មុខរបរ/ការចិញ្ចឹមជីវិត
- ១,៥ ចំនួនអ្នករកចំណូលនៅក្នុងគ្រួសារ
- ១,៦ ចំណូលគ្រួសារក្នុងមួយខែ
- ១,៧ ចំនួនកូនដែលចូលរៀន
- ១,៨ ប្រាក់ប្រចាំថ្ងៃជាមធ្យមដែលឱ្យទៅកូនរបស់ពួកគេ

២, តើគ្រួសារនីមួយៗចំណាយសំរាប់វត្ថុដូចខាងក្រោមចំនួនប៉ុន្មានដើម្បីឱ្យកូនពួកគេបានចូលរៀន?

- ២,១ ចំណាយដើមឆ្នាំ
- ២,២ ថ្លៃសាលា
- ២,៣ ចំណាយប្រចាំថ្ងៃ

២.៤ ចំណាយផ្សេងៗ

៣. តើមានឥទ្ធិពលអ្វីខ្លះចំពោះការចំណាយក្រៅផ្លូវការក្នុងសាលា ពីសំនាក់ក្រុមគ្រួសារនៅតំបន់ទីប្រជុំជន ជនបទ និងដាច់ស្រយាល?

៤. តើអ្វីទៅជាមូលហេតុបណ្តាលអោយកុមារឈប់រៀន?

៥. តើកុមារដែលមិនបានចូលរៀនធ្វើអ្វីខ្លះ?

៦. តើសកម្មភាពអ្វីខ្លះដែលកុមារកំពុងចូលរៀន ហើយជួយដល់គ្រួសារបន្ទាប់ពីការសិក្សា?

### ១.៣.៣ សារៈសំខាន់នៃការសិក្សា

ជាមួយគ្នានេះ ការសិក្សាដទៃទៀតមានបំណងគណនាចំណាយក្រៅផ្លូវការក្នុងការបញ្ជូនកូនទៅរៀនក្នុងប្រទេសកម្ពុជា ការសិក្សាមួយចំនួនតូចទៀតបានស្វែងរកពតិមានដើម្បីធ្វើឯកសារស្តីពីការចំណាយនេះ។ ទោះបីជាទំហំនៃការស្រាវជ្រាវនេះតូច ហើយលទ្ធផលពីការស្រាវជ្រាវនេះ ជាពិសេសតំណាងអោយស្ថានភាពនៅក្នុងខេត្តកំពង់ចាមក៏ដោយ ក៏អាចថាវាតំណាងឱ្យខេត្តដទៃទៀតដែលមានស្ថានភាពសេដ្ឋកិច្ច-សង្គមស្រដៀងគ្នាផងដែរ។ លទ្ធផលនេះអាចប្រើប្រាស់ជាមូលដ្ឋានសំរាប់ប្រៀបធៀបជាមួយខេត្តដទៃទៀត ក្នុងលក្ខខ័ណ្ឌនៃការចំណាយក្រៅផ្លូវការក្នុងសាលាសំរាប់ថ្នាក់អប់រំជាមូលដ្ឋាន និងក៏ជា មូលដ្ឋានសំរាប់ប្រៀបធៀបជាមួយនឹងប្រទេសដទៃទៀតនៅតំបន់អាស៊ីប៉ាស៊ីភិចផងដែរ។ ជាចុងបញ្ចប់លទ្ធផលនេះ អាចធ្វើជាមូលដ្ឋានក្នុងការធ្វើជាសំលេងគំរូ និងគោល-នយោបាយជាក់ស្តែងដែលឆ្លើយតបទៅនឹងគោលបំណង ដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់សេវាអប់រំមូលដ្ឋានដោយមិនគិតថ្លៃដល់កុមារទាំងអស់នៅឆ្នាំ២០១៥។

## ១.៤ វិធីសាស្ត្រ

### ១.៤.១ ទំហំនៃការសិក្សា

នេះជាគំរោងស្រាវជ្រាវនៅថ្នាក់សហគមន៍ ការសិក្សានេះមានបំណងបរិយាយនូវអ្វីដែលកំពុងកើតមានឡើងនៅមូលដ្ឋាន។ ដូច្នេះយើងបានផ្តោតការពិចារណាទៅលើខេត្តមួយគឺ ខេត្តកំពង់ចាម ដោយក្តីសង្ឃឹមការប្រមូលពតិមានស៊ីជុំរៅ ល្អជាងពតិមានដែលផ្អែកលើមូលដ្ឋានទូលំទូលាយ។ ដោយថវិកានៃគំរោង មានកំនត់លទ្ធផលនៃការស្រាវជ្រាវនេះ មិនអាចតំណាងអោយស្ថានភាពទូទាំងប្រទេសឡើយ។ ទោះជាយ៉ាងណាក៏ដោយក្នុងគោលបំណងផ្តល់កេរ្តិ៍ជឿជាក់មួយ យើងបានជ្រើសរើស១០០គ្រួសារដើម្បីធ្វើការសម្ភាសន៍។ ទោះជាទំហំគំរូតូចយ៉ាងណាក៏ដោយ ក៏យើងមានអារម្មណ៍ថាយើងបានប្រមូលទិន្នន័យគ្រប់គ្រាន់ ដែលអាចបង្ហាញពីចំណាត់ថ្នាក់គ្រួសាររស់នៅក្នុងតំបន់ផ្សេងៗគ្នា (ស្រុកទីប្រជុំជន/ជនបទ/ដាច់ស្រយាល) និងស្ថានភាព សេដ្ឋកិច្ចសង្គម ដើម្បីបង្កើតទំនាក់ទំនងលទ្ធផល។ ទោះបីជាគ្រួសារខ្លះមានកូនរៀនថ្នាក់ទី១០ ១១ និងទី១២ ក៏ដោយ តែគោលបំណង

នៃការសិក្សានេះគឺ ធ្វើការវិភាគតែទៅលើទិន្នន័យលើថ្លៃសាលា ដែលចំណាយសំរាប់ កុមារថ្នាក់ទី១ ដល់ទី៩ ប៉ុណ្ណោះ ។

### ១.៤.២ បរិយាកាសនៃការស្រាវជ្រាវ

យោងតាមស្ថានភាពសេដ្ឋកិច្ចសង្គមប្រជាជនខេត្តកំពង់ចាម និងដើម្បីប្រមូលបានពតិមានដែលមានសារៈប្រយោជន៏ និងតំណាងឱ្យក៏រិតវិភាគទានរបស់ឪពុកម្តាយដល់ការអប់រំដើម្បីឱ្យកូនបានរៀនសូត្រ ការស្រាវជ្រាវផ្តោតទៅលើស្រុកដែលបានជ្រើសរើស ដោយផ្អែកលើផ្នែកសំខាន់ៗបីៈ ទីប្រជុំជន ជនបទ និងដាច់ស្រយាល។ ស្រុក៨ ក្នុងចំនោមស្រុកចំនួន១៦ ត្រូវបានជ្រើសរើសសំរាប់ការសិក្សានេះ។ ស្រុកកំពង់ចាម និងត្បូងឃ្មុំត្រូវបានចាត់ទុកថាជាស្រុកទីប្រជុំជន ស្រុកកំពង់សៀម ព្រៃឈរ និងអូរាំងឪ តំណាងអោយជនបទ រីឯស្រុកកោះសូទិន ពញាក្រែក និងក្រូចឆ្មារ តំណាងអោយតំបន់ដាច់ស្រយាល។ វាមានសារៈសំខាន់ក្នុងការកត់សំគាល់ថាការសិក្សានេះធ្វើឡើងក្នុង និងជុំវិញទីរួមស្រុកប៉ុណ្ណោះ។ ពតិមានគឺមិនបានប្រមូលពីកន្លែងនានានៅក្នុងស្រុកដែលឆ្ងាយពីទីប្រជុំជនឡើយ។

ខេត្តកំពង់ចាមគឺត្រូវបានជ្រើសរើសសំរាប់ការសិក្សា ពីព្រោះវាជាខេត្តមួយក្នុងចំណោមខេត្តដែលមានប្រជាជនច្រើនជាងគេ ហើយគឺជាខេត្តដែលមិនមែនទីប្រជុំជនពេក រឺជនបទពេក។ ក៏រិតប្រាក់ចំណូលគឺស្ថិតនៅក្នុងចំនោមខេត្តដែលមានចំណូលជាមធ្យមនៅប្រទេសកម្ពុជា។ ប្រជាជនដែលរស់នៅទីនោះពឹងផ្អែក សំខាន់ទៅលើផលិតផលកសិកម្ម សំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ។ វាស្ថិតនៅក្នុងភូមិសាស្ត្រ ប្រជាសាស្ត្រ និងស្ថានភាពសង្គមសេដ្ឋកិច្ច ដែលចំណាយក្រៅផ្លូវការក្នុងសាលាត្រូវបានរកឃើញ។

### ១.៤.៣ អ្នកឆ្លើយតបចំពោះការស្រាវជ្រាវ

អ្នកឆ្លើយសំនួរអង្កេតគឺ ឪពុកម្តាយ រឺអាណាព្យាបាល និងកូនរបស់គាត់ ដែលបច្ចុប្បន្ននេះកំពុងរៀន។ ឪពុកម្តាយ/អាណាព្យាបាល គឺជាគោលដៅរបស់យើងក្នុងកិច្ចសម្ភាសន៏នេះ ដោយសារតែគាត់ជាអ្នកផ្គត់ផ្គង់ប្រាក់ប្រចាំថ្ងៃដល់កូន និងជាអ្នកផ្គត់ផ្គង់ការចំណាយពាក់ព័ន្ធផ្សេងៗទៀត ក្នុងអំឡុងឆ្នាំសិក្សានីមួយៗ។ ភាគច្រើនគាត់គឺជាអ្នករកចំណូលចំបងសំរាប់គ្រួសារ ដូច្នេះហើយ គាត់គឺជាមនុស្សម្នាក់ដែល នឹងមានអារម្មណ៏ពីផលប៉ះពាល់នៃការចំណាយក្នុងការបញ្ជូនកូនទៅសាលា។ ដូច្នេះយើងចង់ដឹងថា តើឪពុកម្តាយមានអារម្មណ៏យ៉ាងដូចម្តេច អំពីការបញ្ជូនកូនម្នាក់ឱ្យទៅរៀន ហើយតើអ្វីទៅជាតំលៃឱកាសចំពោះពួកគាត់ និងចំពោះគ្រួសារទាំងមូល ក្នុងការបញ្ជូនកូនទៅរៀន។

ចំលើយរបស់កុមារគឺជាប្រភពពតិមាន ដែលមានសក្តានុភាពផងដែរ ព្រោះពួកគេដឹងយ៉ាងលំអិតពីចំណាយជាក់ស្តែង។ ពួកគេអាចប្រាប់យើងផងដែរអំពីទំនាក់ទំនងរបស់គេជាមួយគ្រូបង្រៀន និងសាលារៀន

ចំពោះលុយដែលត្រូវឱ្យគេបង់។ ការឆ្លុះបញ្ចាំងពីតថភាពបច្ចុប្បន្នអំពីការចំណាយរបស់ក្រុមគ្រួសារពិតប្រាកដនៅក្នុងមូលដ្ឋាន យើងបានសួរសំនួរភាគច្រើនពាក់ព័ន្ធថវិកា ទៅសិស្សដែលបច្ចុប្បន្នកំពុងរៀន ជាជាងអ្នកដែលបោះបង់ចោលសាលាហើយ។ យើងក៏បាននិយាយជាមួយសិស្ស ដែលបោះបង់សាលាដើម្បីស្វែងរកមូលហេតុអ្វីបានជាគេបោះបង់សាលា។

រួមមាន១០០គ្រួសារ បានធ្វើសម្ភាសន៍សំរាប់ការសិក្សានេះ ដែល៣៤គ្រួសារមកពីស្រុកទីប្រជុំជន ២៩គ្រួសារមកពីស្រុកជនបទ និង៣៧គ្រួសារមកពីស្រុកដាច់ស្រយាល។ តារាងទី១ បង្ហាញអំពីការបែងចែកចំនួនអ្នកឆ្លើយសំនួរក្នុងទៅតាមស្រុក។

**តារាង១: ការបែងចែកចំនួនអ្នកឆ្លើយសំនួរក្នុងស្រុកនីមួយៗ**

| ល,រ | ស្រុកនានានៅក្នុងខេត្តកំពង់ចាម | ចំនួនគ្រួសារ |
|---|---|---|
| | | |
| ១ | ស្រុកទីប្រជុំជន | |
| | កំពង់ចាម | ១៦ |
| | ត្បូងឃ្មុំ | ១៨ |
| | *សរុបទីប្រជុំជន* | *៣៤* |
| | | |
| ២ | ស្រុកជនបទ | |
| | កំពង់សៀម | ៤ |
| | ព្រៃឈរ | ១០ |
| | អូររាំងឪ | ១៥ |
| | *សរុបជនបទ* | *២៩* |
| | | |
| ៣ | ស្រុកដាច់ស្រយាល | |
| | កោះសូទិន | ២១ |
| | ពញាក្រែក | ១១ |
| | ក្រូចឆ្មារ | ៥ |
| | *សរុបដាច់ស្រយាល* | *៣៧* |
| | | |
| | គំរូសរុប | ១០០ |

### ១.៤.៤ ឧបករណ៍អង្កេត

បញ្ជីសំនួរត្រូវបានប្រើក្នុងការប្រមូលពត៌មានសំខាន់ៗ។ យើងបានរៀបចំការសម្ភាសន៍ផ្ទាល់ ហើយចំលើយត្រូវបានកត់ត្រាដោយអ្នកសម្ភាសន៍។ សំនួរខ្លះមានលក្ខណៈជាសំនួរបិទ ហើយចំលើយភាគច្រើនពាក់ព័ន្ធទៅនឹងស្ថានភាពគ្រួសារ និងចំណូលគ្រួសារដែលធ្វើការចំណាយផ្សេងៗសំរាប់កូនទៅសាលា។ សំនួរខ្លះទៀតជាសំនួរបើកទាក់ទងទៅនឹងផលប៉ះពាល់នៃការចំណាយក្រៅផ្លូវការនៅក្នុងសាលា ទៅនឹងសេចក្តីសំរេចចិត្តរបស់គ្រួសារលើការអប់រំកូន។ អ្នកសម្ភាសន៍ទាំងឡាយត្រូវបានបង្ហាត់អោយសួរសំនួរបន្ថែមទៀតនៅក្នុងស្ថានភាពដែលពត៌មាន អាចមានអត្ថប្រយោជន៍បន្ថែមសំរាប់ការសរសេរករណីរឿងខ្លីៗ។

### ១.៤.៥ នីតិវិធីនៃការប្រមូលទិន្នន័យ

ការរៀបចំការស្រាវជ្រាវក្នុងខេត្តកំពង់ចាមនេះ យើងបានប្រឹក្សាជាមួយអ្នកពាក់ព័ន្ធនានា នៅមូលដ្ឋាន។ យើងបានជួបជាមួយនាយកនាយករងការិយាល័យអប់រំខេត្ត និងអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ដូចជា KAPE។ ជាទូទៅយើងបានទទួលចំលើយពីអ្នកពាក់ព័ន្ធទាំងអស់នេះថា ស្ថានភាពអប់រំមានទំនាក់ទំនង យ៉ាងជិតស្និតជាមួយស្ថានភាពសេដ្ឋកិច្ចគ្រួសារ។

យោងតាមលទ្ធផលនៃកិច្ចសន្ទនានេះ និងការវិភាគពីស្ថានភាពសេដ្ឋកិច្ច-សង្គមទូទៅ បណ្តាស្រុកអង្កេតទាំងនេះត្រូវបានចែកជាបីប្រភេទៈ ស្រុកទីប្រជុំជន ស្រុកជនបទ និងស្រុកដាច់ស្រយាល។ ស្រុកទីប្រជុំជនសំដៅទៅលើស្រុកដែលមានលក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមខ្ពស់។ ផ្ទុយមកវិញស្រុកដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាបបំផុត ត្រូវចាត់ទុកថាជាស្រុកដាច់ស្រយាល រីឯស្រុកជនបទវិញស្ថិតនៅក្នុងចន្លោះប្រភេទទាំង២ខាងលើ។

យើងសំរេចចិត្តសម្ភាសន៍ឪពុកម្តាយជាមួយកូន ព្រមគ្នាដើម្បីធានាក៏រិតនៃការជឿជាក់ លើពត៌មានដែលកំពុងស្វែងរកពាក់ព័ន្ធការចំណាយក្នុងការបញ្ជូនកូនទៅរៀន។ អ្នកឆ្លើយតបត្រូវបានជ្រើសរើសដោយចៃដន្យដោយដើរតាមផ្លូវហើយជ្រើសក្រុមគ្រួសារណាដែលយើងអាចជួប ពេលដែលឪពុកម្តាយ និងកូនៗនៅផ្ទះជុំគ្នា។

ទិន្នន័យប្រមូលបានតាមរយៈការសម្ភាសន៍ ឪពុកម្តាយនិងកូនដែលកំពុងរៀនដោយប្រើកំរងសំនួរមួយ។ កំរងសំនួរធ្វើឡើងដោយគោលបំណងសម្ភាសន៍ឪពុកម្តាយ តែឪពុកក៏រឺក៏ម្តាយ និងកូនក្នុងពេលតែមួយ។ នេះគឺដោយសារតែឪពុកម្តាយភាគច្រើនអាចប្រាប់យើងបានត្រឹមពត៌មានទូទៅ អំពីការចំណាយលើការអប់រំកូនៗរបស់ពួកគេ ប៉ុន្តែកូនអាចផ្តល់ពត៌មានលំអិតពីការចំណាយនៅក្នុងសាលា។

ដោយធ្វើការសម្ភាសន៍ឪពុកម្តាយ និងកូនជាមួយគ្នា យើងអាចប្រមូលបានទិន្នន័យទូលំទូលាយ និងជឿជាក់បាន ព្រោះថាឪពុកម្តាយមិនចាំបាច់ស្មានចំណាយណាដែលគាត់មិនដឹងនោះទេ។ កូនគឺជាប្រភពដ៏ល្អមួយសំរាប់ផ្តល់ពត៌មានអំពីមធ្យោបាយដែលថ្លៃឈ្នួលត្រូវបានប្រមូល និងហេតុផលដែលនាំអោយពួកគេឈប់រៀន។

### ១.៤.៦ ករណីរឿងខ្លីៗជាក់ស្តែង

ដើម្បីបំពេញលទ្ធផលនៃការអង្កេត អ្នកសម្ភាសន៍បានប្រមូលពត៌មានរឿងខ្លីពីបុគ្គលឆ្លើយសំនួរដែលពួកគេយល់ថាសំខាន់ និងជាប្រធានបទពាក់ព័ន្ធនឹងសំនួរដើម្បីឆ្លុះបញ្ចាំងនូវពិតមានផ្នែកគុណភាព។ នៅពេលកំពុងប្រមូលទិន្នន័យក្នុងមូលដ្ឋាន និងពេលដែលជួប ករណីខ្លះដែលឃើញថាសំខាន់នឹងអាចសរសេរជារឿងខ្លីបាន សំរាប់ធ្វើការបង្ហាញពីតថភាពជាក់ស្តែងនៃទិន្នន័យណាមួយនោះ យើងនឹងបន្តសួរសំនួរពាក់ព័ន្ធ ឱ្យស៊ីជម្រៅបន្ថែមទៀតដើម្បីទទួលបានចំលើយលំអិត ។

ពត៌មានរឿងខ្លីនេះត្រូវបានដាក់នៅក្នុងប្រអប់នៅក្នុងតួសេចក្តី ដែលលទ្ធផលជាប់ទាក់ទង និង/រឺ បន្ថែមទៅអោយទិន្នន័យអង្កេត។

### ១.៤.៧ ការវិភាគទិន្នន័យ

ទិន្នន័យត្រូវបានដាក់នៅក្រោមការរាប់ប្រេកង់។ មធ្យមភាគនិងភាគរយត្រូវបានប្រើប្រាស់ក្នុងការវិភាគទិន្នន័យផងដែរ។

## ១.៥ និយមន័យនៃពាក្យគន្លឹះ

*ចំណាយក្រៅផ្លូវការ:* ប្រើក្នុងការសិក្សានេះសំដៅទៅលើចំណាយសម្រាប់ការអប់រំមូលដ្ឋាន ដែលឪពុក-ម្តាយត្រូវចំណាយដើម្បីបញ្ជូនកូនទៅសាលារៀន។ ទាំងនេះគឺជា ចំណាយដំបូង ថ្លៃសាលា ថ្លៃប្រចាំថ្ងៃ និងចំណាយផ្សេងៗ ទៅឱ្យសាលា។

*ចំណាយដើមឆ្នាំ:* គឺជាចំណាយដែលឪពុក-ម្តាយរ៉ាប់រងទាក់ទងទៅនឹងតំរូវការរបស់កូន ក្នុងការរៀបចំខ្លួនចូលរៀន ដូចជា ឯកសណ្ឋានសិស្ស សម្ភារៈសិក្សា និងថ្លៃចុះឈ្មោះចូលរៀន។

*ចំណាយប្រចាំថ្ងៃ:* សំដៅទៅលើចំនួនទឹកប្រាក់ចំណាយដោយឪពុក-ម្តាយសំរាប់ការចំណាយប្រចាំថ្ងៃរបស់កូននៅក្នុងសាលាដូចជា ចំណីអាហារ ផ្ញើរកង់-មូតូ និងមធ្យោបាយធ្វើដំណើរ។

*ថ្លៃសាលា:* សំដៅទៅលើថ្លៃគ្រូបង្រៀន ថ្លៃរៀនគួរ ក្រដាសមេរៀន ក្រដាសប្រឡង។

*ក្មេងដែលទៅរៀន:* នៅក្នុងការសិក្សានេះសំដៅទៅលើ កុមារដែលបានចុះឈ្មោះជាផ្លូវការនៅក្នុងសាលា ហើយនិងកំពុងសិក្សាថ្នាក់អប់រំមូលដ្ឋាន។

*ក្មេងដែលបោះបង់ចោលសាលា:* ប្រើក្នុងការសិក្សានេះសំដៅទៅលើកុមារទាំងឡាយណាដែល បានចុះឈ្មោះចូលរៀន ហើយទៅរៀន ប៉ុន្តែឈប់រៀនដោយមូលហេតុផ្សេងៗ រឺកុមារដែលមិនបានចុះឈ្មោះរៀនទាំងការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

*សម្ភារៈសរសេរ:* រាល់សម្ភារៈផ្សេងៗជាជំនួយដល់ការសរសេរ ដូចជា ប៊ិច ខ្មៅដៃ ជ័រលុប បន្ទាត់។

## ១.៦ ពាក្យសរសេរកាត់ជាភាសាអង់គ្លេស

| | |
|---|---|
| DoE | District Office of Education |
| EDUCAM | Organization that disseminates information to NGOs working in education |
| EFA | Education for All |
| EMIS | Education Management Information System |
| ESP | Education Strategic Plan |
| ESSP | Education Sector Support Program |
| KAPE | Kampuchea Action for Primary Education |
| LSS | Lower Secondary School |
| MoEYS | Ministry of Education Youth and Sport |
| NEP | NGO Education Partnership |
| NGO | Non-Government Organization |
| PAP | Priority Action Program |
| PoE | Provincial Office of Education |
| RGC | Royal Government of Cambodia |
| UNESCO | United Nations Education, Scientific and Cultural Organization |
| UNICEF | United Nations Children’s Fund |
| USS | Upper Secondary School |

# ជំពូក ២
# ការវិភាគ និងការបកស្រាយទិន្នន័យ

ទិន្នន័យត្រូវបានបង្ហាញវិភាគ និងបកស្រាយនៅក្នុងជំពូកនេះ យើងបានរៀបចំជាពីរផ្នែកៈ ១ ) សង្ខេបពីអ្នកជួបសម្ភាសន៍ ២) វិភាគទានរបស់ឪពុកម្ដាយចំពោះការអប់រំដែលមានផ្នែកតូចៗសំរាប់សមាសធាតុផ្សេងៗគ្នានៅក្នុងផ្នែកនីមួយៗ។ ផ្នែកទី១ មានលក្ខណៈត្រង់ និងផ្ដល់នូវការពិពិណនាសង្ខេបៗ។ ផ្នែកទី២ផ្ដល់ពតិមានកាន់តែលំអិត ពីការវិភាគនិងការបកស្រាយអំពីវិភាគទានរបស់ឪពុកម្ដាយចំពោះ ការអប់រំដែលបានរាយការណ៍ដោយឪពុកម្ដាយ និងកូនរបស់ពួកគេ។

## ២.១ សង្ខេបអំពីក្រុមគ្រួសារដែលឆ្លើយតប

### ២.១.១ ទំហំគ្រួសារ

តារាងទី២ បង្ហាញអំពីទំហំគ្រួសារដែលសម្ភាសន៍ នៅក្នុងស្រុកនីមួយៗ។ ទិន្នន័យបង្ហាញថាសមាជិកគ្រួសារមានចាប់ពី ៣ទៅ ១០នាក់។ នៅតំបន់ទីប្រជុំជន និងជនបទគ្រួសារភាគច្រើនមានសមាជិក៤នាក់ រីឯគ្រួសារនៅតំបន់ដាច់ស្រយាលវិញមាន៥នាក់។ ជាមធ្យមនៃសមាជិកគ្រួសារដែល រស់នៅតំបន់ទីប្រជុំជន ជនបទ និងតំបន់ដាច់ស្រយាលក្នុងខេត្តកំពង់ចាមគឺស្ថិតនៅចន្លោះពី ៥ទៅ៦នាក់។

**តារាងទី ២:**ទំហំនិងចំនួនគ្រួសារ ដែលបានផ្ដល់សម្ភាសន៍

| ទំហំគ្រួសារ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | **F** | % | **F** | % | **F** | % | **F** | % |
| ៣ | ១ | ២,៩0 | 0 | 0,00 | ៤ | ១១,៤0 | ៥ | ៥,១0 |
| ៤ | ១0 | ២៩,៤0 | ១0 | ៣៤,៥0 | ៥ | ១៤,៣0 | ២៥ | ២៥,៥0 |
| ៥ | ៧ | ២0,១៦ | ៨ | ២៧,៦0 | ៩ | ២៥,៧0 | ២៤ | ២៤,៥0 |
| ៦ | ៩ | ២៦,៥0 | ១ | ៣,៤0 | ៦ | ១៧,១0 | ១៦ | ១៦,៣0 |
| ៧ | ៣ | ៨,៨0 | ៦ | ២0,៧0 | ៤ | ១១,៤0 | ១៣ | ១៣,៣0 |
| ៨ | ២ | ៥,៩0 | ៤ | ១៣,៨0 | ៤ | ១១,៤0 | ១0 | ១0,២0 |
| ៩ | 0 | 0,00 | 0 | 0,00 | ១ | ២,៩0 | ១ | ១,00 |
| ១0 | ២ | ៥,៩0 | 0 | 0,00 | ២ | ៥,៧0 | ៤ | ៤,១0 |
| សរុប | **៣៤** | ១00 | **២៩** | ១00 | **៣៥** | ១00 | **៩៨** | ១00 |
| មធ្យម | **៥,៥៦** | | **៥,៥២** | | **៥,៧៧** | | **៥,៦២** | |

### ២.១.២ ចំនួនកូនក្នុងគ្រួសារ

តារាងទី៣ បង្ហាញពីចំនួនកូននៅក្នុងគ្រួសារដែលបានផ្តល់សម្ភាស។ ជាទូទៅ គ្រួសារទាំងឡាយដែលបានសួរ មានកូនចាប់ពី ១នាក់ ដល់១០នាក់។ គ្រួសារនៅតំបន់ទីប្រជុំជន និងដាច់ស្រយាលភាគច្រើនមានកូន៣ ទៅ៤នាក់ ហើយភាគច្រើននៃគ្រួសារដែលបានសម្ភាសន៍នៅតំបន់ជនបទ មានកូន ២ ទៅ៣នាក់។ ឯជាមធ្យមនៃគ្រួសារទាំងអស់ដែលឆ្លើយតប ភាគច្រើនមានកូនពី៣ ទៅ៤នាក់។ វាមានសារៈសំខាន់ណាស់ក្នុងការកត់ចំណាំថា គ្រួសារដែលមានកូនចាប់ពី ៥នាក់ឡើងទៅ ច្រើនរស់នៅក្នុងស្រុកដាច់ស្រយាល។

**តារាងទី ៣:** ចំនួនកូនក្នុងមួយគ្រួសារ

| ចំនួនកូន | ទីប្រជុំជន | | ជនបទ | | ដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | % | F | % | F | % | F | % |
| ១ | ២ | ៥,៩0 | ១ | ៣,៤0 | ៣ | ៨,១0 | ៦ | ៦,00 |
| ២ | ៨ | ២៣,៥0 | ១១ | ៣៧,៩0 | ៩ | ២៤,៣0 | ២៨ | ២៨,00 |
| ៣ | ១0 | ២៩,៤0 | ៩ | ៣១,00 | ១0 | ២៧,00 | ២៩ | ២៩,00 |
| ៤ | ៩ | ២៦,៥0 | ២ | ៦,៩0 | ៥ | ១៣,៥0 | ១៦ | ១៦,00 |
| ៥ | ២ | ៥,៩0 | ៦ | ២0,៧0 | ៤ | ១0,៨0 | ១២ | ១២,00 |
| ៦ | 0 | 0,00 | 0 | 0,00 | ១ | ២,៧0 | ១ | ១,00 |
| ៧ | ១ | ២,៩0 | 0 | 0,00 | ៣ | ៨,១0 | ៤ | ៤,00 |
| ៨ | ១ | ២,៩0 | 0 | 0,00 | ១ | ២,៧0 | ២ | ២,00 |
| ៩ | ១ | ២,៩0 | 0 | 0,00 | 0 | 0,00 | ១ | ១,00 |
| ១0 | 0 | 0,00 | 0 | 0, | ១ | ២,៧0 | ១ | ១,00 |
| **សរុប** | **៣៤** | ១00 | **២៩** | ១00 | **៣៧** | ១00 | ១00 | ១00 |
| **មធ្យម** | **៣,៤៧** | | **៣,0៣** | | **៣,៦៨** | | **៣,៤២** | |

### ២.១.៣ កន្លែងដែលកូនដទៃទៀតកំពុងរស់នៅ

តារាងទី៤ បង្ហាញកន្លែងកូនរបស់អ្នកផ្តល់បទសម្ភាសន៍រស់នៅ។ ប្រហែល៧៧%នៃគ្រួសារ មានកូនរស់នៅជាមួយ និង២៣%ទៀតមានកូនរស់នៅឆ្ងាយពីខ្លួន។ នេះសបញ្ជាក់ឱ្យឃើញថាសមាជិកគ្រួសារមួយចំនួនតូច ជាពិសេសកុមារ និងយុវជនផ្លាស់ទីលំនៅចេញពីស្រុកកំណើត។ ប្រមាណមួយភាគបួននៃគ្រួសារ ផ្តល់បទសម្ភាសន៍មានកូនចាកចេញទៅរស់នៅឆ្ងាយពីឪពុកម្តាយ តាមធម្មតាកុមារដែលផ្លាស់ទីលំនៅគឺជាកូនច្បង។ ពួកគេចាកចេញពីផ្ទះដោយមូលហេតុផ្សេងៗ គ្នាដែលមានបង្ហាញក្នុងតារាងទី៥។

**តារាងទី៤:** កន្លែងដែលកូនរស់នៅ

| **ករណី** | **ប្រេកង់(f)** | **ភាគរយ (%)** |
|---|---|---|
| កូនកំពុងរស់នៅជាមួយឪពុកម្តាយ | ៧0 | ៧៧ |
| កូនកំពុងរស់នៅឆ្ងាយពីឪពុកម្តាយៈ នៅក្នុងខេត្តផ្សេងៗ ៤១% នៅភ្នំពេញ ៥៩% | ២១ | ២៣ |
| **សរុប** | **៩១** | ១00 |

**តារាង៥:** មុខរបរ របស់កូនដែលមិនរស់នៅជាមួយឳពុកម្ដាយ

| ល.រ | មុខរបរ | ប្រេកង់ | ភាគរយ |
|---|---|---|---|
| ១ | រៀនមហាវិទ្យាល័យ | ៧ | ៤៤% |
| ២ | ធ្វើការនៅក្នុងរោងចក្រ និងចំការកៅស៊ូ | ៦ | ៣៨% |
| ៣ | ធ្វើជាចុងភៅ | ១ | ៦% |
| ៤ | រៀនសំអាងការ | ១ | ៦% |
| ៥ | រៀបអាពាហ៍ពិពាហ៍ និងលក់នំ | ១ | ៦% |
| **សរុប** | | **១៦** | |

កូនដែលធំពេញវ័យផ្លាស់ទីលំនៅទៅកន្លែងផ្សេងៗក្នុងប្រទេសកម្ពុជា (ភ្នំពេញ សៀមរាប កំពង់ចាម ក្រចេះ បាត់ដំបង ប៉ោយប៉ែត) ជាកន្លែងដែលពួកគេអាចរកការងារធ្វើ ដោយខ្លះបានឆ្លងដែនកម្ពុជា-ថៃ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមយុវជនទាំងនោះមាន៥៩% ទៅរស់នៅឯទីក្រុងភ្នំពេញ ក្នុងនេះមាន៤៤% ទៅទីក្រុងនានាដើម្បីបន្តការសិក្សា ៣៨%ទៀតទៅធ្វើការក្នុងរោងចក្រ។ ពួកគេទាំងអស់ធ្វើការក្នុងផ្នែកផ្សេងៗដូចជា ជាងគ្រឿងចក្រ សំអិតសំអាង ធ្វើម្ហូប។ មួយចំនួនទៀតចាកចេញពីផ្ទះដោយ បានរៀបអាពាហ៍ពិពាហ៍។

### ២.១.៤ មុខរបរឳពុកម្ដាយ

តារាងទី៦ បង្ហាញពីមុខរបររបស់ឳពុកម្ដាយសម្ភាសន៍ ។ទិន្នន័យបង្ហាញថាឳពុកម្ដាយច្រើនជាងគេប្រហែល ៣៦.៦%ជាអ្នកប្រកបអាជីវកម្មធនតូច។ ទិន្នន័យនេះបង្ហាញផងដែរថាចំនួនគ្រួសារដែលប្រកបរបរអាជីវកម្មទាំងនេះ ក្នុងមួយគ្រួសារប្រកបរបរពី១ ទៅ៥ប្រភេទ។ គ្រួសារប្រហែល ២៣.៧%ជាកសិករ និង២០.៥%ជាកម្មករគ្មានជំនាញ។

**តារាងទី៦:** មុខរបរ/ការចិញ្ចឹមជីវិតរបស់ឳពុកម្ដាយ

| មុខរបរ | ប្រេកង់ | ភាគរយ % |
|---|---|---|
| អ្នកប្រកបរបរអាជីវកម្មធនតូច | ៣៤ | ៣៦.៦ |
| គសិករ | ២២ | ២៣.៧ |
| កម្មករ/កម្មករគ្មានជំនាញ | ១៩ | ២០.៥ |
| ប៉ូលីស | ៥ | ៥.៤ |
| គ្រូបង្រៀន | ៣ | ៣.២ |
| ជាងកាត់ដេរ | ៣ | ៣.២ |
| ជាងជួសជុលកង់/ម៉ូតូ | ៣ | ៣.២ |
| មន្ត្រីថែទាំសុខភាព | ២ | ២.២ |
| ម៉ូតូឌុប | ២ | ២.២ |
| **សរុប** | **៩៣** | **១០០%** |

### ២.១.៥ ចំនួនអ្នករកចំណូលនៅក្នុងគ្រួសារ

តារាងទី៧ បង្ហាញចំនួនអ្នករកចំណូលនៅក្នុងគ្រួសារនីមួយៗ។ គ្រួសារមួយចំនួនធំរឺ៦០,៦% មានអ្នករកចំណូលចំនួនពីរនាក់ គឺរកចំណូលទាំងឪពុក និងម្ដាយ រឺឪពុក រឺក៏ម្ដាយជាមួយកូនច្បងធ្វើការដើម្បីរកចំណូលផ្គត់ផ្គង់គ្រួសារ។ តាមការប៉ាន់ប្រមាណថាមានគ្រួសារជាង ២៥% នៅក្នុងប្រទេសកម្ពុជាមានស្ត្រី ជាមេគ្រួសារវាមិនមែនជាការភ្ញាក់ផ្អើលឡើយដែលថាកូនច្បងត្រូវធ្វើការដើម្បីជួយផ្គត់ផ្គង់គ្រួសារ។ (http://www.moc.gov.kh/national_data_resource/)

**តារាងទី៧:** ចំនួនអ្នករកចំណូលនៅក្នុងគ្រួសារ

| **ចំនួនអ្នករកចំនូល** | **ប្រេកង់** | **ភាគរយ (%)** |
|---|---|---|
| ០ | ១ | ១.០ |
| ១ | ២៦ | ២៧.៧ |
| ២ | ៥៧ | ៦០.៦ |
| ៣ | ៦ | ៦.៤ |
| ៤ | ៤ | ៤.៣ |
| **សរុប** | **៩៤** | ១០០ |
| **មធ្យម** | **១.៨៥** | |

**ករណីសិក្សាទី១: ស្ត្រីធ្វើជាមេគ្រួសារ**

ស្ត្រីមេម៉ាយម្នាក់មានកូនបីនាក់ និងម្ដាយចាស់មួយរូបលក់អាហារពេលព្រឹកនៅលើចិញ្ចើមផ្លូវខាងមុខផ្ទះរបស់គាត់តាមមាត់ស្ទឹង។ ប្ដីរបស់គាត់ស្លាប់១០កន្លងមកហើយ។ នៅក្នុងការប្រកបអាជីវកម្មធនតូចនេះ គាត់អាចរកលុយបានពី ៣.០០០ ទៅ៤.០០០រៀល ក្នុងមួយថ្ងៃដែលមិនគ្រប់គ្រាន់សំរាប់ការចិញ្ចឹមជីវិត និងបញ្ជូន កូនទៅរៀនឡើយ។

"សព្វថ្ងៃខ្ញុំបានទទួលការផ្គត់ផ្គង់ខ្លះពីកូនស្រីដែលរស់នៅឯភ្នំពេញជាមួយបងស្រីធមិ។ នាងបានជួយកូនស្រីរបស់ខ្ញុំឱ្យរៀនកាត់សក់នៅភ្នំពេញ។ កូនស្រីខ្ញុំផ្ញើលុយឱ្យ១០០.០០០ ទៅ១៥០.០០០រៀល ($២៥–$៣៧) ក្នុងមួយខែ"។

ស្ត្រីមេម៉ាយបន្ថែមថា "ខ្ញុំមិនចង់ឱ្យកូនឈប់រៀនទេ ប៉ុន្តែខ្ញុំមិនអាចផ្គត់ផ្គង់ពួកគេបាន។ ទោះជាយ៉ាងណាក៏ដោយខ្ញុំប្ដេជ្ញាថាជួយពួកគេយ៉ាងហោចណាស់ឱ្យរៀនចប់ថ្នាក់ទី៩"។ គាត់រៀបរាប់ថា "កូនស្រីទី២របស់ខ្ញុំ ទើបតែឈប់រៀនកាលពីឆ្នាំមុនពេលដែលនាងប្រលងជាប់ថ្នាក់ទី៩។ គ្រូនិងមិត្តភ័ក្ររបស់នាងបានលើកទឹកចិត្ត មិនឱ្យនាងឈប់រៀនប៉ុន្តែខ្ញុំមិនអាចផ្គត់ផ្គង់ឱ្យនាងរៀនតទៅទៀតបានឡើយព្រោះខ្ញុំត្រូវចំណាយច្រើន។

ផ្ទុយមកវិញខ្ញុំយកលុយនេះសន្សំទុកឱ្យនាងរៀនជំនាញមួយ ដើម្បីនាងអាចរស់នៅដោយខ្លួនឯង នាពេល អនាគត។ ខ្ញុំគ្មានទ្រព្យសម្បត្តិសំរាប់ពួកគេទេ ដូច្នេះខ្ញុំខំធ្វើការដើម្បីផ្ដល់ឱ្យពួកគេនូវការអប់រំនិង ជំនាញខ្លះ"។

| |
|---|
| កូនស្រីទី២បច្ចុប្បន្នកំពុងរៀនជំនាញកាត់ដេរ នៅក្នុងរោងជាងឯកជនមួយ នៅទីរួមខេត្តកំពង់ចាម។ នាងមិនទៅសាលាទេ នាងនៅផ្ទះជួយលក់ និងជួយការងារផ្ទះពីព្រោះម្តាយរបស់នាងឈឺ។ នាងចង់ព្យួរការសិក្សា នាងមិនចង់ឈប់រៀនទេ ប៉ុន្តែនាងត្រូវតែធ្វើដូច្នេះពីព្រោះម្តាយរបស់នាងគ្មានប្រាក់ដើម្បីផ្គត់ផ្គង់ថ្លៃទៅរៀន។ |

### ២.១.៦ ចំណូលក្នុងគ្រួសារប្រចាំខែ

តារាងទី៨ បង្ហាញពីចំណូលប្រចាំខែរបស់គ្រួសារសម្ភាសន៍។ ចំណូលប្រចាំខែ មានចន្លោះ ពីទាបជាង១០០.០០០ ទៅច្រើនជាង៨០០.០០០រៀល។ ចំណូលប្រចាំខែជាមធ្យមនៃគ្រួសារនៅក្នុងស្រុកទីប្រជុំជនគឺ ២៧០.០០០រៀល រឺ$៦៧,៥ គ្រួសារជនបទមានចំណូលជាមធ្យម៤៤៤.១១៧រៀល រឺ$១១១,០៣ ក្នុងមួយខែ រឹងគ្រួសារនៅតំបន់ដាច់ស្រយាលរកបាន ៣៥៥.១៨៥ រៀល រឺ $៨៩។ ទិន្នន័យបង្ហាញថាគ្រួសារនៅតំបន់ជនបទរកប្រាក់ចំណូលបានច្រើនជាងគ្រួសារនៅទីប្រជុំជន និងដាច់ស្រយាល។ ចំឡើយអំពីប្រាក់ចំណូល ហាក់ដូចជាមិនប្រាកដ-ជាក់លាក់។ គ្រួសារមួយចំនួនធំ បានជ្រើសរើសមិនឆ្លើយតបទៅនឹងសំនួរនេះ ដែលនេះជាការលំបាកក្នុងការផ្តល់ពត៌មានជាក់លាក់ សំរាប់គណនាភាគរយចំណូលធៀបនឹងការ ចំណាយលើការអប់រំ។

**តារាងទី៨:** ប្រាក់ចំណូលក្នុងមួយខែចំពោះគ្រួសារ

| ចំនួនទឹកប្រាក់ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| តិចជាង ១០០.០០០៛ | ៣ | ១២,០% | ២ | ១១,៨% | ៣ | ១១,១% | ៨ | ១១,៦% |
| ១០០.០០១-២០០.០០០៛ | ៨ | ៣២,០% | ២ | ១១,៨% | ៦ | ២២,២% | ១៦ | ២៣,២% |
| ២០០.០០១-៣០០.០០០៛ | ៥ | ២០,០% | ៤ | ២៣,៥% | ៧ | ២៥,៩% | ១៦ | ២៣,២% |
| ៣០០.០០១-៤០០.០០០៛ | ៦ | ២៤,០% | ០ | ០,០% | ២ | ៧,៤% | ៨ | ១១,៦% |
| ៤០០.០០១-៥០០.០០០៛ | ០ | ០,០% | ១ | ៥,៩% | ១ | ៣,៧% | ២ | ២,៩% |
| ៥០០.០០១-៦០០.០០០៛ | ១ | ៤,០% | ២ | ១១,៨% | ៥ | ១៨,៥% | ៨ | ១១,៦% |
| ៦០០.០០១-៧០០.០០០៛ | ០ | ០,០% | ២ | ១១,៨% | ១ | ៣,៧% | ៣ | ៤,៣% |
| ៧០០.០០១-៨០០.០០០៛ | ២ | ៨,០% | ១ | ៥,1% | ០ | ០,០% | ៣ | ៤,៣% |
| ច្រើនជាង ៨០០.០០០៛ | ០ | ០,០% | ៣ | ១៧,៦% | ២ | ៧,៤% | ៥ | ៧,២% |
| **សរុប** | **២៥** | ១០០% | **១៧** | ១០០% | **២៧** | ១០០% | **៦៩** | ១០០% |
| **មធ្យម (រៀល)<br>$** | | **២៧០.០០០<br>$៦៧,៥** | | **៤៤៤.១១៧<br>$១១១,០៣** | | **៣៥៥.១៨៥<br>$៨៣,៨០** | | **៣៥៦.៤៣៤<br>$៨៩** |

### ២.១.៧ ចំនួនកូនទៅរៀន

តារាងទី៩ បង្ហាញចំនួនកុមារក្នុងមួយគ្រួសារដែលទៅរៀន។ ចំនួនកុមារទៅរៀនមានចន្លោះពី១ ទៅ៥នាក់ ក្នុងមួយគ្រួសារ។ គ្រួសារនៅទីប្រជុំជន និងដាច់ស្រយាលភាគច្រើនបញ្ជូនកូន២ទៅ៣នាក់ទៅរៀន រីឯ

គ្រួសារនៅតំបន់ជនបទបញ្ជូនកូនទៅរៀន១ទៅ២នាក់។ ជាមធ្យម គ្រួសារទីមួយៗបញ្ជូនកូនទៅរៀន២ទៅ៣នាក់។

**តារាងទី៩:** ចំនួនកូនទៅរៀនក្នុងមួយគ្រួសារ

| ចំនួនកូន | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| ១ | ៥ | ១៤,៧% | ៩ | ៣១,0% | ១០ | ២៧,0% | ២៤ | ២៤,0% |
| ២ | ១៧ | ៥0,0% | ១៣ | ៤៤,៨% | ១៤ | ៣៧,៨% | ៤៤ | ៤៤,0% |
| ៣ | ៨ | ២៣,៥% | ៦ | ២0,៧% | ១១ | ២៩,៧% | ២៥ | ២៥,0% |
| ៤ | ៣ | ៨,៨% | ១ | ៣,៤% | ២ | ៥,៤% | ៦ | ៦,0% |
| ៥ | ១ | ២,៩% | 0 | 0,0% | 0 | 0,0% | ១ | ១,0% |
| សរុប | **៣៤** | | **២៩** | | **៣៧** | | ១០០ | |
| មធ្យម | **២,៣៥** | | **១,៩៧** | | **២,១៤** | | **២,១៦** | |

ទិន្នន័យក្នុងតារាងទី១០ បង្ហាញថា ភាគច្រើនកូនដែលមកពីគ្រួសារដែលបានផ្តល់បទសម្ភាសន៍ នៅទីប្រជុំជនរៀនថ្នាក់ទី៧ រីឯគ្រួសារជនបទថ្នាក់ទី៨។ គ្រួសារមកពីតំបន់ដាច់ស្រយាលមានកូនរៀនថ្នាក់ទី៤ និងទី៧។

**តារាងទី ១០:** កុមារចូលរៀនតាមកំរិតថ្នាក់

| ថ្នាក់ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| ថ្នាក់ទី១ | ២ | ៣,៨% | ៣ | ៦,៤% | ៧ | ១០,៩% | ១២ | ៧,៤% |
| ថ្នាក់ទី២ | ៨ | ១៥,៤% | ៤ | ៨,៥% | ៧ | ១០,៩% | ១៩ | ១១,៧% |
| ថ្នាក់ទី៣ | ៧ | ១៣,៥% | ៦ | ១២,៨% | ៤ | ៦,៣% | ១៧ | ១០,៤% |
| ថ្នាក់ទី ៤ | ៦ | ១១,៥% | ៥ | ១០,៦% | ១១ | ១៧,២% | ២២ | ១៣,៥% |
| ថ្នាក់ទី ៥ | ៤ | ៧,៧% | ២ | ៤,៣% | ៦ | ៩,៤% | ១២ | ៧,៤% |
| ថ្នាក់ទី ៦ | ៥ | ៩,៦% | ៤ | ៨,៥% | ៨ | ១២,៥% | ១៧ | ១០,៤% |
| បឋមសិក្សា | ៣២ | | ២៤ | | ៤៣ | | ៩៩ | |
| ថ្នាក់ទី ៧ | ១១ | ២១,២% | ៨ | ១៧,0% | ១១ | ១៧,២% | ៣០ | ១៨,៤% |
| ថ្នាក់ទី ៨ | ៥ | ៩,៦% | ១១ | ២៣,៤% | ៥ | ៧,៨% | ២១ | ១២,៩% |
| ថ្នាក់ទី ៩ | ៤ | ៧,៧% | ៤ | ៨,៥% | ៥ | ៧,៨% | ១៣ | ៨,0% |
| មធ្យមសិក្សា | ២០ | | ២៣ | | ២១ | | ៦៤ | |
| រុប | ៥២ | | ៤៧ | | ៦៤ | | ១៦៣ | |

## ២.១.៨ កុមារបោះបង់សាលា

តារាងទី១១ បង្ហាញថា នៅទីប្រជុំជនកុមារបោះបង់សាលាកើតមានឡើងខ្ពស់បំផុតនៅថ្នាក់ទី៩។ គ្រួសារនៅទីប្រជុំជនទាំងអស់ដែលបានសម្ភាសន៍គ្មាននរណាម្នាក់រាយការណ៍ថាកុមារឈប់រៀនមុនថ្នាក់ទី៧ ឡើយ។ នៅតំបន់ជនបទ កុមារដែលឈប់រៀនមាននៅក៏រិតថ្នាក់ផ្សេងៗគ្នា ទោះបីជាវាមានលក្ខណៈគួរឱ្យកត់សំគាល់ដែលកើតមានខ្ពស់ នៅថ្នាក់ទី៣ និងទី៦ក៏ដោយ។ នៅតំបន់ដាច់ស្រយាលមានសិស្សបោះបង់ការសិក្សាច្រើនជាងតំបន់ទី-ប្រជុំជន និងជនបទ ហើយការបោះបង់កើតមានខ្ពស់នៅថ្នាក់ទី៦។ សិស្សរៀនថ្នាក់ទី៦ និងទី៩ជាទូទៅមានអាយុពី១៣-១៥ឆ្នាំ។

**តារាងទី១១:** កុមារបោះបង់កាសិក្សាពីថ្នាក់ទី១-៩

| ថ្នាក់ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| ថ្នាក់ទី១ | 0 | 0.0% | 0 | 0.0% | ១ | ៦.៣% | ១ | ២.៥% |
| ថ្នាក់ទី២ | 0 | 0.0% | 0 | 0.0% | ១ | ៦.៣% | ១ | ២.៥% |
| ថ្នាក់ទី៣ | 0 | 0.0% | ២ | ១៨.២% | ១ | ៦.៣% | ៣ | ៧.៥% |
| ថ្នាក់ទី ៤ | 0 | 0.0% | ១ | ៩.១% | ១ | ៦.៣% | ២ | ៥.0% |
| ថ្នាក់ទី ៥ | 0 | 0.0% | ២ | ១៨.២% | ២ | ១២.៥% | ៤ | ១0.0% |
| ថ្នាក់ទី ៦ | 0 | 0.0% | ១ | ៩.១% | ៥ | ៣១.៣% | ៦ | ១៥.0% |
| បឋមសិក្សា | 0 | | ៦ | | ១១ | | ១៧ | |
| ថ្នាក់ទី ៧ | ១ | ៧.៧% | ២ | ១៨.២% | ៣ | ១៨.៨% | ៦ | ១៥.0% |
| ថ្នាក់ទី ៨ | ៣ | ២៣.១% | ១ | ៩.១% | 0 | 0.0% | ៤ | ១0.0% |
| ថ្នាក់ទី ៩ | ៩ | ៦៩.២% | ២ | ១៨.២% | ២ | ១២.៥% | ១៣ | ៣២.៥% |
| មធ្យមសិក្សា | ១៣ | | ៥ | | ៥ | | ២៣ | |
| សរុប | ១៣ | | ១១ | | ១៦ | | ៤0 | |

## ២.១.៩ ប្រាក់ប្រចាំថ្ងៃជាមធ្យមសំរាប់ឱ្យកុមារនៅរៀន

*ប្រាក់សំរាប់កូនម្នាក់*

សំនួរមួយក្នុងចំណោមសំនួរទាំងឡាយដែលយើងបានសួរទៅឪពុកម្តាយគឺៈ តើជារៀងរាល់ថ្ងៃពួកគាត់ឱ្យលុយទៅកូនម្នាក់ៗចំនួនប៉ុន្មាន ដើម្បីគ្រប់គ្រាន់សំរាប់ចំណាយដែលពាក់ព័ន្ធទៅនឹងសាលា។ គំនិតនៃសំនួរនេះគឺដើម្បីទទួលបានទស្សនៈជារួមមួយនៃចំនួនលុយដែលឪពុកម្តាយឱ្យទៅកូន ជាទៀងទាត់មុនពេលទៅរៀន។ យើង

បានសាកសួរឪពុកម្តាយផងដែរថា តើចំនួនលុយនេះប្រែប្រួលឬទេ? ឪពុកម្តាយជាច្រើនបានបង្ហាញថា ឱ្យប្រែប្រួលទៅតាមសេចក្តីត្រូវការពួកគេចាំបាច់ ពិសេស១ ពេញមួយឆ្នាំសិក្សា។

តារាងទី១២ បង្ហាញថា គ្រួសារនៅទីប្រជុំជនឱ្យលុយប្រចាំថ្ងៃទៅកូនម្នាក់១ជាមធ្យម ២.៥០០រៀល។ គ្រួសារជនបទឱ្យ១.៨០០រៀលសំរាប់កូនម្នាក់ ហើយគ្រួសារនៅតំបន់ដាច់ស្រយាលអោយ ១.៣០០រៀលសំរាប់កូនម្នាក់។ កុមារយកលុយទៅចំណាយលើការចាយវាយក្នុងសាលា ដែលពាក់ព័ន្ធដូចជា ចំនីអាហារ ការធ្វើដំណើរផ្ញើរកង់មូតូ និងករណីរៀនគួរបន្ថែម។ ការពិភាក្សាយ៉ាងស៊ីជំរៅបន្ថែម ជាមួយកុមារផ្ទាល់បានរៀបរាប់អំពីការចំណាយទាំងអស់ដែលលុយនេះត្រូវចំណាយ។

**តារាងទី១២:** ប្រាក់ប្រចាំថ្ងៃជាមធ្យមសំរាប់កូនម្នាក់

| ប្រាក់ប្រចាំថ្ងៃ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| តិចជាង ១.០០០ | ៨ | ១៦,៣% | ១១ | ២៣,៤% | ៣៤ | ៥៣,១% | ៥៣ | ៣៣,១% |
| ១.០០០-១.៩៩៩ | ១៧ | ៣៤,៧% | ១៩ | ៤០,៤% | ១៥ | ២៣,៤% | ៥១ | ៣១,៩% |
| ២.០០០-២.៩៩៩ | ១១ | ២២,៤% | ៨ | ១៧,០% | ១០ | ១៥,៦% | ២៩ | ១៨,១% |
| ៣.០០០-៣.៩៩៩ | ៧ | ១៤,៣% | ៧ | ១៤,៩% | ៣ | ៤,៧% | ១៧ | ១០,៦% |
| ៤.០០០-៤.៩៩៩ | ១ | ២,០% | ១ | ២,១% | ១ | ១,៦% | ៣ | ១,៩% |
| ៥.០០០-៥.៩៩៩ | ១ | ២,០% | ១ | ២,១% | ១ | ១,៦% | ៣ | ១,៩% |
| ៦.០០០-៦.៩៩៩ | ១ | ២,០% | ០ | ០,០% | ០ | ០,០% | ១ | ០,៦% |
| ៧.០០០-៧.៩៩៩ | ៣ | ៦,១% | ០ | ០,០% | ០ | ០,០% | ៣ | ១,៩% |
| សរុប | ៤៩ | | ៤៧ | | ៦៤ | | ១៦០ | |
| មធ្យម | ២.៤៥៩ | | ១.៨៨៣ | | ១.៣២៨ | | ១.៨៣៨ | |

*ឱ្យលុយកូនទៅរៀន*

តារាងទី១៣ បង្ហាញថាគ្រួសារនីមួយ១នៅតំបន់ទីប្រជុំជនដែលមានកូនរៀនជាមធ្យម២-៣នាក់ចំណាយ ៤.៨០០រៀលលើការឱ្យប្រចាំថ្ងៃ។ គ្រួសារនៅតំបន់ជនបទដែលមានកូនរៀន១-២នាក់ចំណាយ ៣.៦០០រៀល និងនៅតំបន់ដាច់ស្រយាលចំណាយ ២.៤០០រៀល សំរាប់ការឱ្យប្រចាំថ្ងៃទៅកូន២-៣នាក់។

**តារាងទី១៣:** លុយដាក់ហោប៉ៅកូនប្រចាំថ្ងៃ គិតជាមធ្យម ក្នុងមួយគ្រួសារ

| ប្រាក់ប្រចាំថ្ងៃ ក្នុង១ថ្ងៃ | ស្រុកទីប្រជុំជន | | ស្រុកជនបទ | | ស្រុកដាច់ស្រយាល | | សរុប | |
|---|---|---|---|---|---|---|---|---|
| | F | ភាគរយ | F | ភាគរយ | F | ភាគរយ | F | ភាគរយ |
| តិចជាង ១.០០០៛ | ៣ | ៩% | ៥ | ១៧% | ១៣ | ៣៥% | ២១ | ២១% |
| ១.០០១-២.០០០៛ | ៤ | ១២% | ៧ | ២៤% | ៨ | ២២% | ១៩ | ១៩% |
| ២.០០១-៣.០០០៛ | ៤ | ១២% | ២ | ៧% | ៣ | ៨% | ៩ | ៩% |
| ៣.០០១-៤.០០០៛ | ៤ | ១២% | ២ | ៧% | ៧ | ១៩% | ១៣ | ១៣% |
| ៤.០០១-៥.០០០៛ | ១ | ៣% | ៤ | ១៤% | ២ | ៥% | ៧ | ៧% |
| ៥.០០១-៦.០០០៛ | ៥ | ១៥% | ៣ | ១០% | ១ | ៣% | ៩ | ៩% |
| ៦.០០១-៧.០០០៛ | ៤ | ១២% | ៣ | ១០% | ១ | ៣% | ៨ | ៨% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៧.០០១-៨.០០០៛ | ៣ | ៩% | ១ | ៣% | ១ | ៣% | ៥ | ៥% |
| ៨.០០០-១៥.០០០៛ | ៦ | ១៨% | ២ | ៧% | ១ | ៣% | ៩ | ៩% |
| **សរុប** | ៣៤ | | ២៩ | | ៣៧ | | ១០០ | |
| មធ្យម | ៤.៧៩៤ | | ៣.៥៦៩ | | ២.៣៦៥ | | ៣.៥៤០ | |

កាលដែលចំនួនលុយដែលឪពុកម្តាយឱ្យកូន ចាប់ពីតិចជាង១.០០០រៀល ទៅ១៥.០០០រៀលក្នុងមួយថ្ងៃ វាឆ្លុះបញ្ចាំងឱ្យឃើញ ពីស្ថានភាពសេដ្ឋកិច្ចផ្សេងគ្នារបស់ឪពុកម្តាយ ព្រមទាំងក៏ដូចជាការចំណាយខុសគ្នារវាងសិស្សថ្នាក់ទាបនិងសិស្សថ្នាក់ខ្ពស់ ស្រុកទីប្រជុំជន និងស្រុកដាច់ស្រយាលផងដែរ។ ពេលសួរសំនួរបន្ថែមអំពីចំណាយពាក់ព័ន្ធទៅនឹងការចំណាយក្នុងសាលា ឃើញថាប្រាក់ហោប៉ៅ ដែលចំណាយរាល់ថ្ងៃ គ្រាន់តែជាផ្នែកមួយនៃការចំណាយរបស់ឪពុកម្តាយចំពោះការអប់រំកូនរបស់គាត់តែប៉ុណ្ណោះ។

## ២.២ ការចំណាយរបស់ឪពុកម្តាយ

### ២.២.១ ចំណាយដើមឆ្នាំ

ចំណាយដំបូង នៅដើមឆ្នាំសិក្សារួមមាន ឯកសណ្ឋាន សំភារៈសិក្សា និងថ្លៃចុះឈ្មោះចូលរៀន។ សមាសធាតុឯកសណ្ឋានសាលារួមមាន ឯកសណ្ឋានសិស្ស ឯកសណ្ឋានកីឡា ស្បែកជើង/ទ្រនាប់ជើង។ សំភារៈសិក្សាមានសម្លៀក/កាតាប សៀវភៅសរសេរ គម្របសៀវភៅ និងឧបករណ៍សរសេរនានា។ ថ្លៃចុះឈ្មោះចូលរៀនសំដៅលើពាក្យចុះឈ្មោះ រូបថត សៀវភៅតាមដាន ថ្លៃកីឡា និងចំណាយផ្សេងៗ។

#### ២. ២.១.១ ឯកសណ្ឋានសាលា

តារាងទី១៤ បង្ហាញពីចំណាយសំលៀកបំពាក់សិស្សក្នុងមួយឆ្នាំសិក្សាសំរាប់កុមារម្នាក់ៗ ដែលមានឯកសណ្ឋានសិស្ស ឯកសណ្ឋានកីឡា និងស្បែកជើង។ សូមអានសេចក្តីបន្ថែមA-1 បង្ហាញថាឯកសណ្ឋានសិស្សអាចមានចន្លោះពីតិចជាង១០.០០០រៀល ទៅធំបំផុតច្រើនជាង៦០.០០០រៀល ក្នុងមួយឆ្នាំ។ គ្រួសារនៅតំបន់ទីប្រជុំជនភាគច្រើនចំណាយពី៣០.០០០ ទៅ៤០.០០០រៀល ចំពោះសំភារៈទាំងនេះ។ ភាគច្រើននៃគ្រួសារនៅតំបន់ជនបទចំណាយប្រហែលពី១០.០០០ ទៅ៣០.០០០រៀល រីឯនៅតំបន់ដាច់ស្រយាលភាគច្រើនចំណាយតិចជាង១០.០០០ ទៅធំបំផុត២០.០០០រៀល។ ចំណាយសំរាប់ឯកសណ្ឋានសិស្សមានកំរិតខ្ពស់នៅតំបន់ទីប្រជុំជនពីព្រោះកុមារ ភាគច្រើននៃគ្រួសារនៅតំបន់ទីប្រជុំជនដែលបានសម្ភាសន៏រៀនដល់ថ្នាក់ទី៧ រឺឆ្នាំទី១ នៃថ្នាក់មធ្យមសិក្សា។ ឯកសណ្ឋានថ្មីរឺធំៗគឺត្រូវទៅតាមសិស្សពេលគេកាន់តែធំ។ គួសារនៅទីប្រជុំជនចំណាយតិចចំពោះឯកសណ្ឋានសិស្ស កូនរបស់ពួកគាត់ភាគច្រើនរៀនថ្នាក់ទី៨ទៅហើយ ហើយឯកសណ្ឋានចាស់ៗក៏ពួកគេនៅតែអាចប្រើបានដែរ។ ឯកសណ្ឋានសិស្សមានតម្លៃថោកនៅក្នុងតំបន់ដាច់ស្រយាល។ វត្ថុធាតុដើមដើម្បីផលិតឯកសណ្ឋានដែលលក់នៅ

តំបន់ជនបទ និងដាច់ស្រយាលជាធម្មតាថោក ប៉ុន្តែគុណភាពទាប រីឯនៅតំបន់ទីប្រជុំជនសំភារៈមានគុណភាពប្រសើរជាង ប៉ុន្តែតែងតែថ្លៃជាងផងដែរ ។

ជាសរុប ចំពោះឯកសណ្ឋានសាលាដែលចំណាយ ដោយឪពុកម្តាយនៅតំបន់ទីប្រជុំជន ក្នុងកូនម្នាក់គឺ៥៧.៩០០រៀលក្នុងមួយឆ្នាំសិក្សា។ នៅតំបន់ជនបទ និងដាច់ស្រយាលចំណាយគឺ ៥៤.០០០ និង៥១.២០០ រៀល រៀងៗគ្នា។ ម្យ៉ាងទៀត បើប្រៀបធៀបចំណាយលើឯកសណ្ឋានសាលានៅក្នុងតំបន់ទាំងបី គ្រួសារនៅទីប្រជុំជនចំណាយ៧%ខ្ពស់ជាងគ្រួសារនៅតំបន់ជនបទ ហើយគ្រួសារនៅតំបន់ជនបទចំណាយ៤% ច្រើនជាងគ្រួសារនៅតំបន់ដាច់ស្រយាល ។

**តារាងទី១៤:** ចំណាយលើឯកសណ្ឋានសាលាក្នុងមួយឆ្នាំ (គិតជារៀល)

| ចំណាយ | ទីប្រជុំជន | ជនបទ | ដាច់ស្រយាល | ខេត្ត |
|---|---|---|---|---|
| ឯកសណ្ឋានសិស្ស | ២៩.៤១៩ | ២៧.២២២ | ២២.១៦៧ | ២៦.៣០០ |
| ឯកសណ្ឋានកីឡា | ១៥.៨៣៣ | ១១.៣៨៩ | ១៨.៥០០ | ១៥.២០០ |
| ស្បែកជើង | ១២.៦៧២ | ១៥.៣៥៧ | ១០.៥៧៧ | ១២.៩០០ |
| **ចំណាយជាមធ្យមក្នុងកូនម្នាក់** | **៥៧.៩២៤** | **៥៣.៩៦៨** | **៥១.២៤៤** | **៥៤.៤០០** |

ក្រាភិច១ បង្ហាញថាថ្លៃឯកសណ្ឋានសាលាសរុបរួមមានឯកសណ្ឋានសិស្ស៤៨% ឯកសណ្ឋានកីឡា២៨% និងថ្លៃស្បែកជើង២៤% ។ ក្រុមគ្រួសារមួយចំនួនរាយការណ៍ថា ពួកគេមិនមានលទ្ធភាពចំណាយចំពោះសំភារៈមួយចំនួន។ ជាពិសេសខ្លះបានរាយការណ៍ថា ពួកគេមិនមានលទ្ធភាពទិញឯកសណ្ឋានកីឡា ដែលជាការរិះគន់មិនសមហេតុផល ពីគ្រូបង្រៀនមួយចំនួន ធ្វើឱ្យកូនរបស់ពួកគេមិនអាចចូលរួមក្នុងសកម្មភាពកីឡាបាន។

នៅឆ្នាំ១៩៩៩ Brayបានរាយការណ៍ថាឪពុកម្តាយចំណាយជាមធ្យម ៣១.២០០រៀល លើឯកសណ្ឋាន។ បើប្រៀបធៀបថ្លៃចំណាយលើឯកសណ្ឋានជាមធ្យម រាយការណ៍ដោយក្រុមគ្រួសារនៅខេត្តកំពង់ចាមនាពេលនេះនឹងថ្លៃចំណាយលើឯកសណ្ឋានកាលពី៨ឆ្នាំកន្លងទៅដែលរកឃើញដោយBray គឺមានការកើនឡើង៤២%នៅឆ្នាំ ២០០៧។



ក្រាភិច១: ប្រភេទចំណាយលើឯកសណ្ឋានសាលា

### ២.២.១.២ សំភារៈសិក្សា

តារាងទី១៥ បង្ហាញអំពីចំណាយលើសំភារៈសិក្សាដែលរួមមាន សម្លៀត/កាតាប សៀវភៅសរសេរ គំរបសៀវភៅ និងសម្ភារៈសរសេរនានា។ គ្រួសារនៅទីប្រជុំជនបានរាយការណ៍ថាគេចំណាយ ២៥.២០០រៀលសំរាប់សម្លៀត /កាតាប សៀវភៅសរសេរ និងសម្ភារៈសរសេរដែលខ្ពស់ជាងចំនួនទឹកប្រាក់ចំណាយដោយគ្រួសារនៅតំបន់ជនបទ និងដាច់ស្រយាលតែចំនួន២១.៧០០ និង២០.៨០០រៀល រៀងគ្នា។ ឧបសម្ព័ន្ធB1 ដល់B4 បង្ហាញថាភាគច្រើននៃឪពុកម្តាយ ក្នុងស្រុកទាំងអស់ចំណាយប្រចាំឆ្នាំអស់ពី៥.០០០ ទៅ១០.០០០រៀល លើសម្លៀត/កាតាប ពី៧.៥០០ ទៅ១០.០០០រៀល សំរាប់សៀវភៅសរសេរ ពី៥០០ ទៅ១.៥០០រៀល សំរាប់គំរបសៀវភៅ និងពី១.៥០០ ទៅ៣.០០០រៀលសំរាប់សម្ភារៈសរសេរ។

បើប្រៀបធៀបថ្លៃសំភារៈសិក្សាទៅតាមស្រុក គ្រួសារនៅតំបន់ទីប្រជុំជនចំណាយ១៦% ច្រើនជាងការចំណាយដោយគ្រួសារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ ការចំណាយរបស់គ្រួសារជនបទ សំរាប់សម្ភារៈទាំងនេះគឺ៤% ខ្ពស់ជាងចំនួនចំណាយដោយគ្រួសារនៅតំបន់ដាច់ស្រយាល។

**តារាងទី ១៥:** ថ្លៃចំណាយលើសម្ភារៈសិក្សាសម្រាប់កូនម្នាក់ ក្នុងពេលមួយឆ្នាំ

| ចំណាយលើ | ទីប្រជុំជន | ជនបទ | ដាច់ស្រយាល | ខេត្ត |
|---|---|---|---|---|
| សម្លៀត/កាតាប | ១០.៩៣៨ | ៨.៣១១ | ៨.០៤៣ | ៩.១០០ |
| សៀវភៅសរសេរ | ៩.៤១៧ | ៨.៤៦៦ | ៨.៨៣៣ | ៨.៩០០ |
| គំរបសៀវភៅ | ១.០១២ | ១.១៣១ | ៩៥៤ | ១.០០០ |
| ឧបករណ៍សរសេរ | ៣.៨៤១ | ៣.៨២៥ | ៣.០០០ | ៣.៦០០ |
| **ចំណាយជាមធ្យមក្នុងកូនម្នាក់** | **២៥.២០៨** | **២១.៧៣៣** | **២០.៨៣០** | **២២.៦០០** |

ក្រាភិច២ បង្ហាញថា ៤១% នៃចំណាយលើសំភារៈសិក្សា គឺសំរាប់សម្លៀត និងកាតាប។ ប្រហែល៣៩% សំរាប់សៀវភៅសរសេរ និង១៦%គឺឧបករណ៍សរសេរ។ ក្នុងករណីខ្លះក្រុមគ្រួសារដែលមានចំណូលទាបបានឱ្យដឹងថា ពួកគេមិនទិញសម្លៀតអោយកូនសំរាប់ដាក់សៀវភៅទេ គេឱ្យកូនប្រើថង់ប្លាស្ទិចជំនួស។




**ក្រាភិច២: ប្រភេទចំណាយលើសម្ភារៈសិក្សា**

### ២.២.១.៣ ថ្លៃចុះឈ្មោះចូលរៀន

ថ្លៃចុះឈ្មោះចូលរៀនរួមមានការចំណាយសំរាប់ពាក្យចុះឈ្មោះ រូបថត សៀវភៅព្រឹត្តបតិពន្ធ ថ្លៃកីឡា និងថ្លៃផ្សេងៗ។ ប្រេកង់ចំណាយរបស់គ្រួសារសំរាប់ថ្លៃចុះឈ្មោះ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធC1 ដល់C4 បង្ហាញថា ឪពុកម្តាយនៅទីប្រជុំជនចំណាយជាមធ្យម ១.០០០រៀលសំរាប់ពាក្យចុះឈ្មោះ។ គ្រួសារនៅជនបទចំណាយប្រហែល៦០០រៀល ហើយគ្រួសារនៅតំបន់ដាច់ស្រយាលចំណាយ២៥០រៀល។ ពាក្យចូលរៀន គឺចែកឱ្យដោយមិនិគិតថ្លៃ ប៉ុន្តែសិស្សមួយចំនួនត្រូវចំណាយសំរាប់វា។ ការបំពេញពាក្យចូលរៀនដោយគ្រូ សិស្សត្រូវចំណាយបន្ថែម៦០០រៀលទៀត។ ទិន្នន័យនេះបង្ហាញថាឪពុកម្តាយនៅតំបន់ទីប្រជុំជន និងជនបទភាគច្រើនចំណាយ ២.០០០ រៀលសំរាប់រូបថតផងដែរ។ សាលាតំរូវឱ្យមានរូបថតដើម្បីធ្វើប័ណ្ណសំគាល់ខ្លួនសិស្ស និងពាក្យផ្សេងៗ ដូចជា សៀវភៅតាមដាន និងពាក្យចុះឈ្មោះចូលរៀន។

សៀវភៅតាមដានមានតំលៃប្រហែល៤០០ទៅ ៦៥០រៀល។ សៀវភៅតាមដាននេះកត់ត្រារដំណើររីកចំរើនរបស់សិស្សម្នាក់ៗ។ សៀវភៅតាមដាននេះប្រើជាយន្តការរាយការណ៍មួយ សំរាប់អោយគ្រូរាយការណ៍ពីការរីកចំរើនរបស់សិស្សទៅអោយឪពុកម្តាយ។ គ្រួសារមួយចំនួនបានរាយការណ៍ថាសាលាបានយកលុយ សំរាប់សៀវភៅតាមដានរឺឯអ្នកដទៃទេនិយាយថាសៀវភៅតាមដានមិនគិតលុយទេ ប៉ុន្តែគិតលើគំរបប្លាស្ទិច។ សិស្សមួយចំនួនធំនិយាយថាគេត្រូវបង់ថ្លៃប្រចាំខែពី៣០០រៀល ទៅ៥០០រៀល ផងដែរ សំរាប់ឱ្យគ្រូបំពេញសៀវភៅតាមដាន ដើម្បីផ្ញើរទៅផ្ទះជូនឪពុកម្តាយ។ ថ្លៃកីឡា និងថ្លៃផ្សេងៗទៀតស្ថិតក្នុងចន្លោះពី៨០០ ទៅ១.០០០រៀល។

តារាងទី១៦ បង្ហាញពីថ្លៃចុះឈ្មោះចូលរៀនសរុប ដែលជាសមាសភាពនៃចំណាយដំបូង។ ទិន្នន័យបង្ហាញថា គ្រួសារនៅតំបន់ជនបទចំណាយខ្ពស់ជាងគេ សំរាប់វត្ថុអស់ទាំងនេះ ចំនួន៥.៩០០រៀលក្នុងមួយឆ្នាំ បើប្រៀបធៀបជាមួយចំណាយរបស់គ្រួសារនៅតំបន់ទីប្រជុំជនគឺ៥.៤០០រៀល និង៤.៧០០រៀលសំរាប់គ្រួសារ នៅតំបន់ដាច់ស្រយាល។

**តារាងទី១៦:** ថ្លៃចុះឈ្មោះចូលរៀនសរុប សម្រាប់កូនម្នាក់

| ចំណាយ | ទីប្រជុំជន | ជនបទ | ដាច់ស្រយាល | ថ្នាក់ខេត្ត |
|---|---|---|---|---|
| ពាក្យចុះឈ្មោះ | ១.៦៤៥ | ១.៣៩២ | ៥០០ | ១.២០០ |
| រូបថត | ២.២០៥ | ២.៨៤៧ | ២.៧៣៥ | ២.៦០០ |
| សៀវភៅតាមដាន | ៥៣៤ | ៨៣៩ | ៦៥៦ | ៧០០ |
| កីឡា និងថ្លៃផ្សេងៗ | ១.០០០ | ៨០០ | ៨២៥ | ៩០០ |
| **ចំណាយជាមធ្យមសំរាប់កូនម្នាក់** | **៥.៣៨៤** | **៥.៨៧៨** | **៤.៧១៦** | **៥.៤០០** |

ក្រាភិច៣បង្ហាញថាការចំណាយលើរូបថតស្មើ ៤៨% នៃចំណាយចុះឈ្មោះចូលរៀនសរុប។ ដូច្នេះពាក្យចុះឈ្មោះមាន ២២% កីឡា និងចំណាយផ្សេងៗ ១៧% និងសៀវភៅតាមដាន១៣%។




ក្រាភិច៣: ប្រភេទចំណាយលើការចុះឈ្មោះចូលរៀន

**ករណីសិក្សាទី២: សៀវភៅតាមដាន**

នៅខេត្តកំពង់ចាម ពេលដែលចូលរៀនដំបូងនៅថ្នាក់មធ្យមសិក្សា សិស្សត្រូវបង់ថ្លៃដើម្បីបានសៀវភៅតាមដានដែលវាត្រូវរ៉ាប់រងដោយថវិកាPAP។ "កុមារីអាយុ១៣ឆ្នាំម្នាក់ បាននិយាយថានាងចំណាយ៦០០រៀលសំរាប់សៀវភៅតាម ដានរបស់នាង រួមបញ្ចូល១០០រៀលសំរាប់គំរបសៀវភៅ។"

នៅកន្លែងមួយចំនួនទៀត សៀវភៅតាមដានចែកដោយមិនគិតលុយ ប៉ុន្តែសិស្សត្រូវតែចំណាយលុយមួយចំនួនបន្ថែមពី១០០ ទៅ៣០០រៀលធ្វើគំរបប្លាស្ទិច។ តាមសំដីរបស់សិស្សម្នាក់នៅស្រុកត្បូងឃ្មុំនិយាយថា "សាលាឱ្យខ្ញុំបង់៣០០រៀល សំរាប់គំរបសៀវភៅតាមដាន" "ខ្ញុំគ្រាន់តែចំណាយលុយ បន្ទាប់មកសាលានឹងរៀបចំគំរបសៀវភៅឱ្យ។"

អ្វីដែលគួរអោយចាប់អារម្មណ៍នោះគឺសិស្សត្រូវតែបង់៣០០ ទៅ៥០០រៀល ជារៀងរាល់ខែពេលដែលសៀវភៅតាមដាន បញ្ជូនដល់ឪពុកម្តាយ។ កុមារីអាយុ១៣ឆ្នាំ ជារៀនថ្នាក់ទី៧ក្នុងស្រុកត្បូងឃ្មុំនិយាយថា នាងត្រូវតែបង់ប្រាក់៥០០រៀលជារៀងរាល់ខែអោយគ្រូរបស់នាង ពេលដែលគ្រូប្រគល់សៀវភៅដល់នាង ដើម្បីផ្ញើរអោយឪពុកម្តាយ។ នាងបន្ថែមទៀតថា "លុយនេះត្រូវតែបង់" ។

### ២.២.១.៤ សង្ខេបប្រាក់ចំណាយដើមឆ្នាំ

តារាងទី៧ បង្ហាញអោយឃើញអំពីចំណាយនៅដើមឆ្នាំសរុប ដែលឪពុកម្តាយបានចំណាយនៅតាមតំបន់ទាំងបី។ ចំណាយនៅដើមឆ្នាំ ចែកចេញជាបីប្រភេទៈ ឯកសណ្ឋាន សម្ភារៈសិក្សា និងការចុះឈ្មោះចូលរៀន។ គ្រួសារនៅទីប្រជុំជនចំណាយ៨៨.៥០០រៀល លើចំណាយដើមឆ្នាំសំរាប់កូនម្នាក់ៗ ចំណែកឯគ្រួសារតំបន់ជនបទ និងតំបន់ដាច់ស្រយាលចំណាយតែ៨១. ៦០០រៀល និង៧៦.៧០០រៀល។

**តារាងទី ១៧:** ចំណាយដើមឆ្នាំសំរាប់កូនម្នាក់ចូលរៀនក្នុង ១ឆ្នាំ

| ចំណាយ | ប្រជុំជន | ជនបទ | ដាច់ស្រយាល | ថ្នាក់ខេត្ត |
|---|---|---|---|---|
| ឯកសណ្ឋាន | ៥៧.៩០០ | ៥៤.000 | ៥១.២០០ | ៥៤.៤០០ |
| សម្ភារៈសិក្សា | ២៥.២០០ | ២១.៧០០ | ២០.៨០០ | ២២.៦០០ |
| ការចុះឈ្មោះចូលរៀន | ៥.400 | ៥.៩០០ | ៤.៧០០ | ៥.៤០០ |
| ចំណាយជាមធ្យមក្នុងកូនម្នាក់ | **៨៨.500** | **៨១.៦០០** | **៧៦.៧០០** | **៨២.៤០០** |

ការប្រៀបធៀបនៃចំណាយដើមឆ្នាំសំរាប់កូនម្នាក់ បានបង្ហាញថា គ្រួសារ នៅទីប្រជុំជនចំណាយ៨.៥% ខ្ពស់ជាងគ្រួសារនៅតំបន់ជនបទ។ ឯគ្រួសារនៅតំបន់ដាច់ស្រយាលចំណាយតិចជាងគេទៅលើចំណាយនេះ។

ក្រាភិច៤ បង្ហាញឱ្យឃើញថាចំណាយលើឯកសណ្ឋានមានចំនួន៦៦%នៃចំណាយដើមឆ្នាំសរុប។ សម្ភារៈសិក្សាមានតែ២៧% ហើយការចុះឈ្មោះចូលរៀនមានតែ៧% នៃចំណាយដើមឆ្នាំសរុប។ ជាធម្មតាចំណាយទាំងនេះកើតមានឡើងតែម្តងប៉ុណ្ណោះគឺនៅដើមឆ្នាំសិក្សា។ ចំណាយខាងដើមទៅលើខ្ទង់ចំណាយទាំង អស់នេះអាចជាឧបសគ្គទៅដល់គ្រួសារដែលមានជីវភាពក្រីក្រខ្លាំង ដើម្បីឱ្យកូនទៅរៀនតាំងពីដំបូង។



ក្រាភិច ៤: ប្រភេទនៃចំណាយដើមឆ្នាំ

## ២.២.២ ចំណាយលើការសិក្សា

ចំណាយលើការសិក្សា គឺជាប្រភេទចំណាយដែលសិស្សបង់ថ្លៃគ្រូបង្រៀន ថ្លៃរៀនគួរ ក្រដាសមេរៀន និងក្រដាសប្រលង។ នៅក្នុងឧបសម្ព័ន្ធD1 និងD2 រួមមានទូវចំណាយប្រចាំថ្ងៃដែលគ្រួសារចំណាយលើថ្លៃគ្រូបង្រៀន និងថ្លៃរៀនគួរ ។

### ២.២.២.១ ថ្លៃគ្រូបង្រៀន

ទិន្នន័យបង្ហាញឱ្យឃើញថា សិស្សម្នាក់ត្រូវចំណាយពី១០០-២០០រៀលក្នុង១ថ្ងៃ ទៅលើថ្លៃគ្រូបង្រៀន ហើយសិស្សម្នាក់ៗត្រូវចំណាយបន្ថែមទៅលើថ្លៃរៀនគួរពី២០០- ២.០០០រៀលក្នុង១ថ្ងៃ។ ឧបសម្ព័ន្ធD3 និងD4 បង្ហាញអោយឃើញថាការចំណាយប្រចាំឆ្នាំទៅលើ ក្រដាសមេរៀន និងក្រដាសប្រលងមានពី ១.០០០-២១.០០០ រៀលហើយអាចមានពី ១.០០០រៀល រហូតខ្ពស់បំផុតទៅដល់៣០.០០០រៀល ។

### ២.២.២.២ ការរៀនគួរបន្ថែម

តារាង៨ បង្ហាញថាភាគច្រើននៃការចំណាយទៅលើការសិក្សាគឺ ចំណាយលើការរៀនគួរច្រើនជាងគេ។ ថ្លៃរៀនគួរបានផ្តល់ទៅឱ្យគ្រូ ដែលបើកបង្រៀនថ្នាក់ក្រៅម៉ោង។ ជួនកាល ថ្នាក់រៀនក្រៅម៉ោងទាំងនេះ គេបើកបង្រៀននៅក្នុងម៉ោងរដ្ឋក៏មាន ហើយខ្លះទៀតធ្វើនៅកន្លែងឯកជនផ្សេងៗនៅក្នុងសហគមន៍។ ជាមធ្យម គ្រួសារនៅទីប្រជុំជនចំណាយ២១៣.៤០០រៀល ក្នុង១ឆ្នាំ លើការសិក្សានេះ ចំណែកឯគ្រួសារនៅទីជនបទចំណាយ ២៣៥.៥០០រៀល ហើយគ្រួសារនៅតំបន់ដាច់ស្រយាលចំណាយ១៧៩.៥០០រៀល។ បើប្រៀបធៀបចំណាយលើការរៀនគួរនៅតំបន់ទាំងបីបង្ហាញថា គ្រួសារនៅតំបន់ជនបទចំណាយលើថ្លៃសិក្សាខ្ពស់ជាងគេ បើធៀបនឹងគ្រួសារនៅទីប្រជុំជន និងតំបន់ដាច់ស្រយាល។ សិស្សក្នុងគ្រួសារមានជីវភាពខ្វះខាតមិនអាចរៀនថ្នាក់ក្រៅម៉ោងបានទេ ដែលពួកគេ អាចធ្លាក់នូវមុខវិជ្ជាដែលគេមិនបានរៀនគួរ ហើយទីបញ្ចប់អាចនាំពួកគេបោះបង់ការសិក្សា ។

សិស្សជាច្រើនបានប្រាប់អោយដឹងថា មេរៀនដែលគ្រូបង្រៀននៅថ្នាក់ក្រៅម៉ោង គឺភាគច្រើនជាការបង្រៀនបន្តពីកម្មវិធីសិក្សារបស់រដ្ឋ មិនមែនការបង្រៀនមុខវិជ្ជាបន្ថែមនោះទេ។ ប្រសិនបើគេមិនរៀនថ្នាក់ក្រៅម៉ោងទេគេនឹងខកខានមិនបានរៀនផ្នែកសំខាន់ៗក្នុងកម្មវិធីសិក្សារបស់រដ្ឋ និងជារឿយៗគេរៀនមិនទាន់សិស្សដទៃទៀតដែលរៀនក្រៅម៉ោង។ មេរៀនបង្រៀននៅថ្នាក់ក្រៅម៉ោង ភាគច្រើនផ្តោតសំខាន់ទៅដល់ការត្រៀមប្រលងផងដែរ ឯសិស្សដែលមិនបានរៀនក្នុងថ្នាក់ក្រៅម៉ោងជានិច្ចកាល មិនសូវបានពិន្ទុល្អទេនៅពេលប្រលង។

ជាលទ្ធផលសិស្សទាំងអស់នេះត្រូវរៀនត្រួតថ្នាក់ ។ Bray បានកត់សំគាល់ឃើញថា នៅពេលថ្នាក់ក្រៅម៉ោងត្រូវបានទទួលស្គាល់ដោយប្រព័ន្ធអប់រំកម្ពុជានោះ "វានឹងមានផលលំបាកជាច្រើន" សំរាប់សិស្សដែលគ្មានលទ្ធភាពរៀនគួរ ផលលំបាកទាំងនោះរួមមាន: ការជំពាក់ទាក់ទងនឹងការដាក់ទណ្ឌកម្មចំពោះ សិស្សក្រីក្រដែលមិនអាចបង់ថ្លៃរៀនគួរ ហើយបរាជ័យ និងការបោះបង់ការសិក្សានឹងកើតមានចំពោះសិស្សដែលឪពុកម្តាយរបស់គេ មិនមានលទ្ធភាពឱ្យកូនរៀនគួរបន្ថែម ។ Bray ក៏បានកត់សំគាល់ឃើញថាឪពុកម្តាយជាច្រើន នៅកម្ពុជាបានទទួយយកការបង្រៀនថ្នាក់ក្រៅម៉ោងនេះ ។ បើគិតពិចារណាទៅលើក៏រិតប្រាក់បៀវត្សន៍ របស់គ្រូបង្រៀននាបច្ចុប្បន្ន វាមិនអាចឆ្លើយតបនឹងតំរូវការសេដ្ឋកិច្ចគ្រួសារជាក់ស្តែង របស់គ្រូបង្រៀន (Bray, ១៩៩៩) ។

**តារាងទី ១៨:** ចំណាយលើការសិក្សាសំរាប់កូនម្នាក់ ក្នុង១ឆ្នាំ

| ចំណាយ | ប្រជុំជន | ជនបទ | ដាច់ស្រយាល | ថ្នាក់ខេត្ត |
|---|---|---|---|---|
| ថ្លៃគ្រូបង្រៀន | ២៩.៨០៨ | ៣២.៤០០ | ២៥.២៧២ | ២៩.២០០ |
| ថ្លៃរៀនគួរ | ១៦៨.០៤៨ | ១៨៤.៦៨០ | ១៣៨.០២៤ | ១៦៣.៦០០ |
| ក្រដាសមេរៀន | ៧.១២៥ | ៩.៥០០ | ៧.៦៨៨ | ៨.១០០ |
| ក្រដាសប្រលង | ៨.៣៧០ | ៨.៩៥២ | ៨.៥០០ | ៨.៦០០ |
| ចំណាយជាមធ្យមសំរាប់កូនម្នាក់ | ២១៣.៤០០ | ២៣៥.៥០០ | ១៧៩.៥០០ | ២០៩.៥០០ |

ក្រាភិច៩ បង្ហាញអំពីចំណាយទៅលើការរៀនក្រៅម៉ោងមាន៧៨% នៃចំណាយសរុប ហើយចំណាយលើថ្លៃគ្រូបង្រៀនមាន១៤% ហើយចំណាយលើក្រដាសមេរៀន និងក្រដាសប្រលងមានត្រឹមតែ៤% ។ វាបង្ហាញយ៉ាងច្បាស់ថា ឪពុកម្តាយត្រូវចំណាយទៅលើការបង្រៀនក្រៅម៉ោងយ៉ាងច្រើនសន្ធឹក សន្ធាប់ដែលធ្វើអោយពួកគាត់មានអារម្មណ៍ថា ជាការបង្ខំចិត្តត្រូវតែបង់ដើម្បីធានាភាពជោគជ័យរបស់កូនគាត់ ។




**ក្រាភិច ៩:** ប្រភេទនៃចំណាយលើការសិក្សា

**ករណីសិក្សាទី៣: មិនអាចផ្គត់ផ្គង់លើ ឯកសណ្ឋាន និងចំណាយលើការសិក្សា**

កុមារីម្នាក់អាយុ១៤ឆ្នាំ រៀននៅថ្នាក់ទី៧ នៅក្នុងស្រុកព្រៃឈរ។ នាង និងបងប្រុសម្នាក់ទៀត ជាកូនប្អូនគេនៅក្នុងគ្រួសារ។ បងប្រុស និងបងស្រីដទៃទៀតបានរៀបការ និងមានគ្រួសារផ្ទាល់ខ្លួនអស់ហើយ។ ឪពុកម្តាយរបស់នាងមានអាយុជាង៥០ឆ្នាំប្លាយ។ បងប្រុសរបស់នាងបានឈប់រៀនកាលពីឆ្នាំទៅ ត្រឹមថ្នាក់ទី៨។

ជារៀងរាល់ព្រឹកនាងទៅសាលារៀន និងចេញពីរៀននៅម៉ោង១១។ ពេលមកដល់ផ្ទះនាងត្រូវដាំបាយនិងរងចាំឪពុកយកបន្លែ និងសាច់ ឬត្រីមក ទើបនាងអាចចំអិនម្ហូបសំរាប់អាហារថ្ងៃត្រង់។ ឪពុកនាង ប្រកបមុខរបរជាអ្នករត់ម៉ូតូឌុប។ គាត់ទៅរត់ម៉ូតូឌុបនៅឯផ្សាររហូតដល់ពេលបាយថ្ងៃត្រង់ ទើបគាត់អាចទិញ ម្ហូបយកមកផ្ទះ ។

ម្តាយរបស់នាងមិនបានចំអិនម្ហូបទេ ពីព្រោះគាត់ចង់នៅដេរសំលៀកបំពាក់ឱ្យបានច្រើនរហូត លើសពេលអាហារថ្ងៃត្រង់ដើម្បីអោយគាត់រកកំរៃបន្ថែមទៀត ។

កុមារីនេះបានរៀនថ្នាក់ក្រៅម៉ោងជាមួយអ្នកគ្រូរបស់នាង។ នាងចំណាយ៥០០រៀល ក្នុង១ថ្ងៃ ប៉ុន្តែឥលូវនេះនាងមិនបានចូលរៀនទៀតទេ ព្រោះនាងអត់មានប្រាក់។ នៅពេលដែលនាងឈប់ទៅរៀនគួរពីរបីថ្ងៃ អ្នកគ្រូរបស់នាងបានសួរ "ហេតុអ្វីបានជាឯងឈប់មករៀនគួរ" នាងមានការខ្មាស់អៀនយ៉ាងខ្លាំង។ បន្ទាប់មក នាងឆ្លើយថា "ខ្ញុំឈប់ទៅរៀនដោយសារតែខ្ញុំគ្មានប្រាក់បង់គួរ "

ការអត់ប្រាក់ គឺជាហេតុផលមួយដែលធ្វើអោយកុមារីបោះបង់ការសិក្សាក្រៅម៉ោង។ ហេតុផល មួយទៀតនោះគឺដោយសារតែនាងគ្មានពេលគ្រប់គ្រាន់។ នាងត្រូវនៅធ្វើម្ហូប ហើយបោកខោអាវ បន្ទាប់ពីញុំាបាយថ្ងៃត្រង់រួច បន្ទាប់ពីនាងធ្វើការងារទាំងអស់នេះរួចវាខកពេលទៅរៀន។

កុមារីបន្ថែមថា "ខ្ញុំនឹងឈប់រៀននៅឆ្នាំក្រោយនេះហើយ ពីព្រោះខ្ញុំគ្មានប្រាក់ ហើយខ្ញុំត្រូវធ្វើការ ដើម្បីជួយឪពុកម្តាយរបស់ខ្ញុំ"។ "ខ្ញុំត្រូវទិញសៀវភៅ សម្ភារៈសិក្សាផ្សេងៗ ក្រដាសមេរៀន និងក្រដាសប្រលង"។ ឪពុកម្តាយខ្ញុំទិញកង់ចាស់មួយឱ្យខ្ញុំមានតំលៃ ៥០.០០០រៀល ចំណែកឯងកសណ្ឋានសិស្សអ្នកជិតខាងជាអ្នកឱ្យ"។

## ២.២.៣ ចំណាយប្រចាំថ្ងៃ

ឧបសម្ព័ន្ធE1 និងE2 បង្ហាញឱ្យឃើញថា ឪពុកម្តាយចំណាយពី៦០០-១.២០០រៀល ទៅលើនំចំណី និងពី ១០០-១៥៧រៀលក្នុង១ថ្ងៃ លើថ្លៃផ្ញើយានជំនិះសំរាប់កូនម្នាក់។ តារាង១៩ បង្ហាញអោយឃើញអំពីចំណាយប្រចាំឆ្នាំ លើប្រភេទចំណាយខាងលើសំរាប់កូនម្នាក់។ ឪពុកម្តាយចំណាយមួយភាគធំនៃប្រាក់ចំណូលរបស់ខ្លួនទៅលើអាហារ និងនំចំណី។ ទោះបីជាBray បានជំទាស់ថាចំណាយលើអាហារ និងនំចំណីគឺជាចំណាយដែលឪពុកម្តាយគួរតែទទួលខុសត្រូវក៏ដោយ ក៏មានភស្តុតាងជាច្រើនបង្ហាញឱ្យឃើញការពិតថាគ្រូតែងតែលក់នំចំណីឱ្យសិស្ស ហើយគាត់ពឹងផ្អែកលើការលក់នំចំណីនេះដើម្បីបន្ថែមទៅលើប្រាក់បៀវត្សន៍តិចតួចរបស់ពួកគាត់។ លើសនេះទៀត សិស្សមួយចំនួននិយាយថាប្រសិនបើគេមិនបានជួយទិញនំចំណីគ្រូ គេនឹងអាចរៀនត្រួតថ្នាក់នៅចុងឆ្នាំ។ Bray ក៏ឱ្យដឹងដែរថាការចំណាយលើនំចំណីរបស់កូននៅផ្ទះវាថោកជាងការទិញនំចំណីនៅខាងក្រៅឆ្ងាយណាស់។

តារាង១៩ បានឱ្យដឹងថា នៅទីប្រជុំជនកុមារម្នាក់ចំណាយប្រហែល២៨៨.០០០រៀល ប្រចាំថ្ងៃនៅក្នុងរយៈពេល១ឆ្នាំសិក្សា។ ចំណែកកុមារនៅតំបន់ជនបទចំណាយ ២៦៤.០០០រៀលនៅក្នុង១ឆ្នាំសិក្សា និងកុមារនៅតំបន់ដាច់ស្រយាលចំណាយអស់ជាងពាក់កណ្ដាលនៃអ្វីដែលចំណាយដោយកុមារនៅទីប្រជុំជន ។

**តារាង ១៩:** ចំណាយប្រចាំថ្ងៃក្នុងកូនម្នាក់ ក្នុង១ឆ្នាំ

| ចំណាយ | ប្រជុំជន | ជនបទ | ដាច់ស្រយាល | ថ្នាក់ខេត្ត |
|---|---|---|---|---|
| ចំណីអាហារ | ២៦៦.៩៧៦ | ២៣០.២៥៦ | ១៤២.៣៤៤ | ២១៣.២០០ |
| ថ្លៃលើការចតយានជំនិះ | ២១.៦០០ | ៣៣.៩០០ | ២៧.៤០០ | ២៧.៦០០ |
| ចំណាយជាមធ្យមសំរាប់កូនម្នាក់ | ២៨៨.៦០០ | ២៦៤.២០០ | ១៦៩.៧០០ | ២៤០.៨០០ |

**ករណីសិក្សាទី៤: អ្នកគ្រូលក់នំចំណី ក្នុងថ្នាក់រៀន**

ម្ដាយម្នាក់ មានកូនប្រុសអាយុ១២ឆ្នាំ រៀននៅថ្នាក់ទី៥ នៅក្នុងស្រុកព្រៃឈរ បានមានប្រសាសន៍ថា គាត់ចង់ឱ្យកូនប្រុសគាត់ឈប់រៀនជាមួយគ្រូស្រីទៀតហើយ ពីព្រោះគ្រូស្រីតែងតែប្រើកូនគាត់ឱ្យលក់នំនៅក្នុងថ្នាក់រៀន ហើយឱ្យកូនគាត់ទៅផ្សារជួយទិញនំចំណីគាត់ទៀត។ គាត់មានប្រសាសន៍ថា "កូនគាត់មិន បាច់ចូលរៀនទេ នៅពេលប្រលង អ្នកគ្រូឱ្យពិន្ទុខ្ពស់ ហើយកូនគាត់ជាប់លេខមួយនៅក្នុងថ្នាក់ "។ គាត់បន្ថែមទៀតថា "កូនរបស់ខ្ញុំជាប់លេខមួយនៅក្នុងថ្នាក់ ប៉ុន្តែវាមិនបានរៀនអ្វីទេ"។

## ២.២.៤ ចំណាយដទៃទៀត

ចំណាយដទៃទៀតរួមមាន សម្ភារៈសិក្សា សម្ភារៈថ្នាក់រៀន ការជួសជុលកង់ ទិញកាដូជូនគ្រូ ដាក់លុយឱ្យគ្រូពេលយកសៀវភៅតាមដានឱ្យគាត់ និងចូលបុណ្យផ្សេងៗក្នុងសាលា។ ទាំងនេះជាចំណាយមិនប្រចាំថ្ងៃ ដែលសិស្សត្រូវបង់ក្នុងអំឡុងពេល១ឆ្នាំ។ ក្នុងឧបសម្ព័ន្ធF1 និងF6 បង្ហាញអំពីចំណាយ របស់គ្រួសារលើចំណាយដទៃទៀត។ ទិន្នន័យបង្ហាញឱ្យឃើញថា ជាមធ្យមគ្រួសារភាគច្រើនចំណាយតិចជាង៦.០០០រៀល លើសម្ភារៈសិក្សា ៨០០រៀលលើសម្ភារៈថ្នាក់រៀន ឯចំណាយលើការជួសជុលកង់អស់ពី២.០០០រៀល ដល់លើស១០.០០០រៀល។ ការទិញកាដូជូនគ្រូមានពី១.០០០រៀល ដល់លើសពី៦.០០០រៀល ក្នុង១ឆ្នាំ។ ថ្លៃសៀវភៅតាមដាន ឱ្យគ្រូអស់ពី ៩០០ ដល់៤.៥០០រៀល សំរាប់កូនម្នាក់។ ការចំណាយលើពិធីផ្សេងៗមានចាប់ពី១០០រៀល ដល់២.៥០០រៀល សំរាប់កូនម្នាក់ក្នុង១ឆ្នាំ។

ជាមធ្យម គ្រួសារជាច្រើននៅទីប្រជុំជន ចំណាយច្រើនជាងគ្រួសារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ទៅលើប្រភេទចំណាយដទៃទៀត ហើយអាចឆ្លុះបញ្ចាំងអំពីលទ្ធភាពរបស់គ្រួសារនីមួយៗនៅតាមតំបន់ផ្សេងៗគ្នា លើការចំណាយទាំងអស់នេះ។ ភាពខុសគ្នារវាងចំណាយទាំងអស់នេះ ក៏មានលក្ខណៈខុសគ្នា ផងដែរ

ពីស្រុកមួយទៅស្រុកមួយ និងចំលើយដែលផ្តល់ឱ្យគឺវាអាស្រ័យលើតំរូវការរបស់គ្រូម្នាក់ៗ ជាការខិតខំប្រឹងប្រែងដើម្បីបំពេញបន្ថែមលើប្រាក់បៀវត្សន៍ដ៏តិចតួចដែលឱ្យដោយរដ្ឋាភិបាល ។

**តារាង ២០:** ចំណាយដទៃទៀតក្នុងកូនម្នាក់ ក្នុង១ឆ្នាំ

| ចំណាយ | ទីប្រជុំជន | ជនបទ | ដាច់ស្រយាល | ថ្នាក់ខេត្ត |
|---|---|---|---|---|
| សម្ភារៈសិក្សា | ៦.២៩៥ | ៤.៥៦៨ | ៥.១៩៧ | ៥.៣០០ |
| សម្ភារៈថ្នាក់រៀន | ៧៥០ | ៧៦៩ | ៧៦៩ | ៨០០ |
| ថ្លៃជួសជុលកង់ | ៦.២៥០ | ៤.៧៧៣ | ៤.០០០ | ៥.០០០ |
| ទិញកាដូជូនគ្រូ | ៤.៨៧៥ | ៤.០០០ | ១.៥០០ | ៣.៥០០ |
| ការយកសៀវភៅតាមដានអោយគ្រូ | ៣.៩៨៦ | ៣.៦០០ | ១.៦២០ | ៣.១០០ |
| ពិធីបុណ្យផ្សេងៗ | ១.៣៣៣ | ១.១៤៣ | ១.១៦៩ | ១.២០០ |
| សរុបចំណាយជាមធ្យមក្នុងកូនម្នាក់ | ២៣.៤០០ | ១៨.៩០០ | ១៤.២០០ | ១៨.៩០០ |




**ក្រាភិច ៦:** ប្រភេទនៃចំណាយដទៃទៀត

ការសិក្សាស្រាវជ្រាវរបស់យើងក៏បានរកឃើញ មានចំណាយផ្សេងៗទៀតវាអាស្រ័យទៅលើសាលារៀន និងគ្រូ។ តារាង២០ បង្ហាញថា ដោយសារចំណាយទាំងអស់នេះមិនមែនជាចំណាយប្រចាំថ្ងៃ តែមានចំនួនច្រើនជាមធ្យមចំណាយទាំងនេះមានចាប់ពី១៤.៣០០រៀល ទៅ២៣.៤០០រៀលក្នុង១ឆ្នាំ សំរាប់កូនម្នាក់។

ចំពោះកូនអ្នកក្រវិញ ចំណាយទាំងនេះអាចបង្កជាបញ្ហា ប្រសិនបើគេគ្មានលទ្ធភាពបង់នោះ។ ឧទាហរណ៍មួយគឺការចំណាយប្រាក់ដើម្បីបានពិន្ទុឡើងថ្នាក់នៅក្នុងម៉ោងហត្ថកម្ម ដែលគ្រូដាក់ពិន្ទុយោងទៅលើសម្ភារៈដែលទិញពីផ្សារ។ គំនិតដំបូងរបស់ម៉ោងហត្ថកម្មគឺ សិស្សម្នាក់ៗត្រូវរៀនធ្វើ ឫផលិតរបស់ផ្សេងៗនៅក្នុងថ្នាក់ដែលជាផ្នែកមួយនៃមេរៀនបំនិនជីវិត។ ប៉ុន្តែផ្ទុយមកវិញយ៉ាងហោចណាស់មាន សាលារៀនមួយចំនួន បានប្រែក្លាយសកម្មភាពកសាងជំនាញខាងហត្ថកម្ម ទៅជាឱកាស សំរាប់គ្រូបង្រៀន តម្រូវឱ្យសិស្សទិញសម្ភារៈ របស់របរពីផ្សារទៅវិញ។

## ករណីសិក្សាទី៥: ចំណាយលើមុខវិជ្ជាហត្ថកម្ម

កុមារីអាយុ១៣ឆ្នាំម្នាក់ រៀនថ្នាក់ទី៦ និយាយថាក្នុងមួយថ្ងៃម្តាយនាងអោយលុយ១.០០០រៀល ទៅសាលារៀន។ នាងចំណាយ១០០រៀល ជូនឱ្យគ្រូបង្រៀន និង៥០០រៀលសំរាប់រៀនគួរជាមួយគ្រូដដែលនោះ ហើយ៤០០រៀលទៀត ចាយលើអាហារ និងនំចំណី។

បន្ថែមលើនេះទៅទៀត សាលារៀនតំរូវឱ្យសិស្សទាំងអស់ធ្វើការងារហត្ថកម្ម ដែលការងារនេះគ្រូជាអ្នកដាក់ពិន្ទុឱ្យសិស្សប្រចាំខែ។ សិស្សទាំងអស់ត្រូវទិញរបស់របរ ដូចជា កញ្ចើ សាប៊ូ សារ៉ុង ថ្នាំដុសធ្មេញពីគ្រូ ដើម្បីបានពិន្ទុសំរាប់មុខវិជ្ជាហត្ថកម្ម។ “បើទិញរបស់របរកាន់តែថ្លៃ អ្នកនឹងទទួលពិន្ទុកាន់តែច្រើន”។ តាមធម្មតានាងតែងតែទិញ ថ្នាំដុសធ្មេញ ឬសាប៊ូ ដែលមានតំលៃពី៣.០០០ ដល់៤.០០០រៀល។ ចំណែកមិត្តនាង គេអាចទិញរបស់ថ្លៃជាងដូចជា សារ៉ុង គេបានពិន្ទុខ្ពស់ជាង។

នាងបានបន្ថែមថា សិស្សទាំងអស់នៅក្នុងថ្នាក់នាងត្រូវទិញកាដូជូនគ្រូយ៉ាងហោចណាស់ម្តងក្នុង១ឆ្នាំ។ តាមធម្មតានាងទិញកាដូដែលមានតំលៃប្រហែល៧.០០០រៀល។

## ២.៣ ផលប៉ះពាល់នៃចំណាយក្រៅផ្លូវការលើការចំណាយរបស់គ្រួសារ

គោលដៅមួយដែលការស្រាវជ្រាវនេះចង់ដឹងនោះគឺ ផលប៉ះពាល់នៃចំណាយក្រៅផ្លូវការ លើគ្រួសារផ្នែកហិរញ្ញវត្ថុ និងការបាត់បង់ឱកាសដល់គ្រួសារ និងកូនរបស់ពួកគេ។

យោងលើផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ តារាង២១ បង្ហាញអំពីការចំណាយក្រៅផ្លូវការជាមធ្យមសរុបរបស់ឪពុកម្តាយក្នុងការបញ្ជូនកូនម្នាក់ឱ្យទៅរៀននៅអនុវិទ្យាល័យ និងបឋមសិក្សាសាធារណៈ។ ទិន្នន័យបានឱ្យដឹងថា ជាមធ្យមក្នុងមួយឆ្នាំឪពុកម្តាយនៅតំបន់ទីប្រជុំជនចំណាយ៦១៣.៩០០រៀល($១៥៣) ដើម្បីបញ្ជូនកូនម្នាក់ទៅរៀនសាលារដ្ឋ ឬត្រូវជា១៩% នៃប្រាក់ចំនូលរបស់គ្រួសារ។ ឯនៅតំបន់ជនបទចំណាយ ៦០០.២០០រៀល ($១៥០) សំរាប់កូនម្នាក់ ត្រូវជា១១%នៃប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំរបស់។ ចំណែកនៅតំបន់ដាច់ស្រយាល ចំណាយ ៤៤០.១០០រៀល ($១១០) ត្រូវជា១០% នៃប្រាក់ ចំណូលគ្រួសារប្រចាំឆ្នាំ ។

**តារាង ២១:** ចំណាយក្រៅផ្លូវការសំរាប់កូនម្នាក់ ក្នុង១ឆ្នាំ

| ស្រុក | ចំណូលមធ្យមប្រចាំឆ្នាំ(ជារៀល) | ចំណាយដើមឆ្នាំ | ចំណាយលើការសិក្សា | ចំណាយប្រចាំថ្ងៃ | ចំណាយផ្សេងៗ | ចំណាយសរុបសំរាប់កូនម្នាក់ក្នុង១ឆ្នាំ (ជារៀល) | ភាគរយ |
|---|---|---|---|---|---|---|---|
| ប្រជុំជន | ៣.២៤០.០០០ | | | | | ៦១៣.៩០០ | |
| | ($៨១០) | ៨៨.៥០០ | ២១៣.៤០០ | ២៨៨.៦០០ | ២៣.៤០០ | $ ១៥៣ | ១៩% |
| ជនបទ | ៥.៣២៩.៤០៤ | | | | | ៦០០.២០០ | |
| | ($១.៣៣២) | ៨១.៦០០ | ២៣៥.៥០០ | ២៦៤.២០០ | ១៨.៩០០ | $ ១៥០ | ១១% |
| ដាច់ស្រយាល | ៤.២៦២.២២០ | | | | | ៤៤០.១០០ | |
| | ($១.០៦៦) | ៧៦.៧០០ | ១៧៩.៥០០ | ១៦៩.៧០០ | ១៤.២០០ | $ ១១០ | ១០% |
| | ៤.២៧៧.២០៨ | | | | | ៥៥១.៤០០ | |
| មធ្យម | ($១.០៦៩) | ៨២.៣០០ | ២០៩.៥០០ | ២៤០.៨០០ | ១៨.៨០០ | $ ១៣៨ | ១៣% |

ដូច្នេះ ការបញ្ជូនកូនម្នាក់ឱ្យទៅរៀននៅថ្នាក់អប់រំមូលដ្ឋាន គេត្រូវចំណាយជាមធ្យមពី១០% ទៅ១៥% នៃប្រាក់ចំណូលគ្រួសារ។ ចំណាយនេះនឹងកើនឡើងអាស្រ័យនឹងចំនួនកូនដែលឪពុកម្តាយ បញ្ជូនឱ្យទៅរៀននៅថ្នាក់បឋមសិក្សា និងនៅពេលពួកគេឡើងដល់ថ្នាក់អនុវិទ្យាល័យ។

ដោយយោងលើការបាត់បង់ឱកាសដល់គ្រួសារ និងកូនៗ យើងបានសាកសួរឪពុកម្តាយ និងកូន នូវសំនួរជាក់ស្តែងមួយចំនួន ឱ្យគាត់ពិចារណាក្នុងការសំរេចចិត្ត ចំពោះកូនដែលមិនបានទៅរៀន ឬបោះបង់ការសិក្សា។ ការសិក្សាមួយអំពីសិស្សដែលបោះបង់ការសិក្សានៅក្នុងខេត្តកំពត របស់ Katherine Roberts បានរកឃើញថា ចំណាយក្រៅផ្លូវការគឺ ជាហេតុផលដ៏ចំបងមួយនាំឱ្យសិស្សបោះបង់ការសិក្សា។ ចំណាយលើការរៀនគួរបន្ថែម ទិញនំចំណី និងចំណាយប្រចាំថ្ងៃឱ្យគ្រូបង្រៀនជាហេតុផល ដ៏សំខាន់នាំឱ្យសិស្សឈប់រៀន។ ហេតុផលដទៃទៀតរួមមាន សាលារៀននៅឆ្ងាយពីផ្ទះ និងត្រូវជួយធ្វើការងារគ្រួសារ។ ការសិក្សារបស់Roberts ក៏បានបង្ហាញដែរថា ៥៦%នៃសិស្សដែលគាត់បានសម្ភាសន៍ ដែលពួកគេបានឈប់រៀនហើយនោះ និយាយថាពួកគេចង់ចូលរៀនវិញ។ (Roberts, 2006)

ការសិក្សាស្រាវជ្រាវនៅពេលថ្មីៗនេះបានអះអាងការរកឃើញរបស់Roberts នៅក្នុងការសម្ភាសន៍ ឪពុកម្តាយ និងកូន ដោយមានឈ្មោះថា "ភាពក្រីក្រ និងការមិនមានប្រាក់ចំណាយលើការសិក្សា" គឺជាហេតុផលមួយនាំឱ្យកុមារសំរេចចិត្តបោះបង់ការសិក្សា។ ហេតុផលផ្សេងៗទៀតមាន ការប្រលងធ្លាក់ កុមារត្រូវរកកំរៃឱ្យគ្រួសារ និងការមិនចាប់អារម្មណ៍ចំពោះការសិក្សា។ កុមារមួយចំនួនទៀតបាននិយាយថា គេត្រូវធ្វើការរកលុយដោយខ្លួនឯងដើម្បីរៀន និងគ្មានពេលវេលាគ្រប់គ្រាន់ទៅរៀនទាន់ពេល។

**ករណីសិក្សាទី៦: គ្មានប្រាក់ និងពេលវេលាគ្រប់គ្រាន់ទៅរៀន**

រៀងរាល់ព្រឹក បូរ៉ា ភ្ញាក់ពីព្រលឹម ទៅលីបន្លែ និងតវ៉ាន់ផ្សេងៗឱ្យអ្នកលក់នៅឯផ្សារ។ ជាធម្មតាបូរ៉ា រកលុយបានពី ២.០០០ ទៅ៣.០០០រៀល ក្នុងមួយថ្ងៃ។ គ្រួសារបូរ៉ាមានជីវភាពក្រីក្រ គ្មានប្រាក់គ្រប់គ្រាន់ដើម្បីទៅរៀន ដូច្នេះហើយទើបបូរ៉ាក្រោកពីព្រលឹម និងទៅរកប្រាក់ដោយខ្លួនឯង។ ពេលបូរ៉ាធ្វើការចប់វាដល់ម៉ោង៧ កន្លះទៅហើយ បូរ៉ា ព្យាយាមទៅរៀនជារៀងរាល់ថ្ងៃទោះបើទៅយឺតក៏ដោយ។ ក្រោយមកបូរ៉ា ក៏សំរេចចិត្តឈប់រៀន ដោយសារមានការលំបាករកប្រាក់ និងទៅរៀនមិនទាន់ពេល។ បូរ៉ាឈប់រៀនកាលពីឆ្នាំមុន នៅពេលគាត់រៀនថ្នាក់ទី៨ ឥលូវបូរ៉ាមានអាយុ ១៧ឆ្នាំ។

## ២.៣.១ កុមារនៅកំពុងសិក្សា និងកុមារបោះបង់ការសិក្សា

### ២.៣.១.១ មូលហេតុដែលបណ្តាលឱ្យកុមារបោះបង់ការសិក្សា

តារាង២២ បង្ហាញពីមូលហេតុដែលបណ្តាលអោយកុមារបោះបង់ការសិក្សា។ កត្តាបង្កឱ្យសិស្សបោះបង់ការសិក្សា រួមមាន: ជាញឹកញាប់សិស្សភាគច្រើនឈប់ទៅរៀនក៏ដោយសារគ្រួសាររបស់គេមានជីវភាពក្រីក្រ មិនអាចផ្គត់ផ្គង់ទៅលើការចំណាយផ្សេងៗទាក់ទងនឹងការសិក្សា។ ក្នុងចំណោមសិស្សដែល ឱ្យបទសម្ភាសន៍ទាំងអស់

មាន៤០% និយាយថាគេឈប់រៀនក៏ដោយសារតែហេតុផលសេដ្ឋកិច្ច។ ជាពិសេស សិស្សជាច្រើននាក់និយាយថា គេគ្មានប្រាក់បង់ចំណាយលើការសិក្សាប្រចាំថ្ងៃ និងបង់ឱ្យថ្លៃរៀនគួរបន្ថែម។

ដូចដែលគ្រួសារភាគច្រើនបានរាយការណ៍មកនោះ ជោគជ័យនៅក្នុងការសិក្សារបស់កូនគាត់ ជារឿយៗ អាស្រ័យទៅលើលទ្ធភាពក្នុងការបង់ថ្លៃរៀនគួរបន្ថែមក្រៅពីម៉ោងរដ្ឋ។ ចំពោះសិស្សផ្សេងៗទៀតដែលមិនមាន លទ្ធភាពរៀនគួរបន្ថែម ភាគច្រើនគេប្រលងធ្លាក់ និងរៀនត្រួតថ្នាក់។ ការបរាជ័យទាំងនេះ ធ្វើឱ្យពួកគេមាន អារម្មណ៍គិតថា គេអត់មានបញ្ញា ឬក៏គ្មានសមត្ថភាពដើម្បីបំពេញតំរូវការរបស់សាលារៀន។ បញ្ហានេះ បានធ្វើ ឱ្យគេបាក់ទឹកចិត្តក្នុងការបញ្ចប់ការអប់រំថ្នាក់មូលដ្ឋាន និងធ្វើឱ្យគេទទួលបានត្រឹមតែការងារដែលមានប្រាក់ខែទាប និងគ្មាននិរន្តរភាពជារៀងរហូត។

**តារាង ២២:** មូលហេតុដែលបណ្តាលអោយកុមារឈប់រៀន

| មូលហេតុដែលបណ្តាលអោយកុមារឈប់រៀន | ប្រេកង់ | ភាគរយ |
|---|---|---|
| គ្រួសារក្រីក្រ និងគ្មានប្រាក់គ្រប់គ្រាន់ | ១០ | ៤០% |
| កុមារប្រលងធ្លាក់ | ៥ | ២០% |
| កុមារត្រូវជួយរកប្រាក់ចំណូលក្នុងគ្រួសារ | ៣ | ១២% |
| កុមារគ្មានចំណាប់អារម្មណ៍ទៅសាលារៀន | ៣ | ១២% |
| កុមារមិនសូវវៃឆ្លាត និងគ្មានលទ្ធភាព | ២ | ៨% |
| កុមារទទួលពិការភាព | ១ | ៤% |
| សាលារៀនមានការគ្រប់គ្រងមិនសូវល្អ | ១ | ៤% |
| សរុប | ២៥ | ១០០% |

**ករណីសិក្សាទី៧: មិនរៀនគួរបន្ថែមនឹងរៀនត្រួតថ្នាក់**

យើងបានសម្ភាសន៍យុវជនម្នាក់អាយុ១៧ឆ្នាំ គាត់គឺជាកូនប្រុសតែមួយគត់នៅក្នុងគ្រួសារដោយមាន ប្អូនស្រីពីរនាក់ ម្នាក់រៀននៅថ្នាក់ទី៣ និងម្នាក់ទៀតរៀនថ្នាក់ទី២។ ម្តាយរបស់គាត់នៅផ្ទះ ឪពុកគាត់ ជាកម្មករ។ គាត់រកប្រាក់បានប្រហែល ៥.០០០រៀលក្នុងមួយថ្ងៃ។ ពួកគេគានផ្ទះផ្ទាល់ខ្លួនទេ ហើយជ្រកកោននៅជាមួយអ៊ីស្រីនៅឃុំ បឹងកុក ក្នុងក្រុងកំពង់ចាម។

បច្ចុប្បន្ន យុវជនរូបនេះមិនបានរៀនសូត្រទេ។ គាត់បានឈប់រៀនកាលពីឆ្នាំទៅនៅពេលរៀនដល់ថ្នាក់ទី៨។ គាត់ និយាយថា" ខ្ញុំសំរេចចិត្តឈប់រៀនក៏ដោយសារតែខ្ញុំគ្មានប្រាក់បង់រៀនគួបន្ថែម"។ គាត់បន្តទៀតថា"បើសិនជាយើងមិនរៀន គួរបន្ថែមទេ យើងមិនអាចឡើងថ្នាក់បានទេ" ម្យ៉ាងវិញទៀត គ្រួសារមានជីវភាពលំបាកយ៉ាប់យឺន ដូច្នេះហើយទើបគាត់ឈប់ រៀនដើម្បីជួយរកប្រាក់ជួយគ្រួសារ ។

យមុននេះយុវជន រូបនេះ រកការងារបានធ្វើនៅផ្ទះសំណាក់មួយនៅក្នុងក្រុងកំពង់ចាម។ នៅទីនោះគាត់ទទួលប្រាក់ ខែ៥០.០០០រៀល ($១២.៥០)ក្នុងមួយខែ។ តែឥលូវនេះគាត់អត់មានការងារធ្វើទេ ។

### ២.៣.១.២ សិស្សដែលបោះបង់ការសិក្សា កំពុងធ្វើអ្វីខ្លះ

**តារាង ២៣:** សការងាររបស់សិស្សដែលបោះបង់ការសិក្សា

| សកម្មភាពការងាររបស់សិស្សដែលបោះបង់ការសិក្សា | ប្រេកង់ | ភាគរយ |
|---|---|---|
| ជួយរកប្រាក់ឱ្យឪពុកម្ដាយរបស់គេ | ៧ | ៣៥% |
| ធ្វើការនៅក្នុងរោងចក្រកាត់ដេរ ផ្ទះសំណាក់ ។ល។ | ៧ | ៣៥% |
| ជួយលក់ត្រីនៅផ្សារជាដើម | ៤ | ២០% |
| ធ្វើកសិកម្ម | ២ | ១០% |
| សរុប | ២០ | ១០០% |

កុមារដែលបោះបង់ការសិក្សា បានធ្វើការងារផ្សេងៗគ្នាដើម្បីជួយបង្កើនចំណូលគ្រួសារ។ កុមារជាច្រើនឈប់រៀននៅថ្នាក់ទី៦ និងទី៩ ដែលក្មេងប្រុសស្រីទាំងនោះមានអាយុ១២ ដល់១៥ឆ្នាំ ហើយគេចាប់ផ្ដើមស្វែងរកការងារធ្វើដើម្បីជួយជីវភាពគ្រួសារ។ ក្មេងប្រុសឈប់រៀនដើម្បីជួយឪពុកម្ដាយ លើការងារកសិកម្មប្រចាំគ្រួសារ ឬ ការងារដែលទាក់ទងនឹងសកម្មភាពបង្កើតប្រាក់ចំណូលដល់គ្រួសារ ចំណែកឯក្មេងស្រីវិញតែងតែឈប់រៀនដើម្បីធ្វើការងារផ្ទះ និងមើលថែទាំប្អូន។ ប៉ុន្តែការស្រាវជ្រាវនេះមិនបង្ហាញទំនាក់ទំនងរវាងការងារ និងយេនឌ័រទេ។

**ករណីសិក្សាទី៨: ចំណាយលើការសិក្សា និងការមើលថែទាំប្អូនៗ**

យុវជនម្នាក់អាយុ១៦ឆ្នាំ គឺជាកូនច្បងនៅក្នុងគ្រួសារដែលមានកូនប្រាំនាក់សុទ្ធតែប្រុស។ យុវជរូបនេះ ឥឡូវរៀននៅថ្នាក់ទី៧ ហើយប្អូនប្រុសពីរនាក់ទៀតក៏កំពុងសិក្សាផងដែរ។ នៅក្នុងគ្រួសារនេះមានសមាជិកប្រាំបីនាក់ រួមទាំងឪពុកម្ដាយ និងជីដូន ពួកគេរស់នៅក្នុងស្រុកកំពង់សៀម។ យុវជននេះទៅសាលារៀនមិន ទៀតទាត់ទេសព្វថ្ងៃនេះពីព្រោះគាត់ត្រូវនៅជួយមើលថែទាំប្អូនៗ នៅពេលជីដូនទៅផ្សារ និងចំអិនម្ហូប។ ម្ដាយ របស់គាត់ជាជាងអ៊ុតសក់ ដែលពេលថ្មីៗនេះគាត់ទើបសំរាលកូនប្រុសម្នាក់ទៀត ដូច្នេះគាត់មិនទាន់អាចទៅធ្វើការវិញទេ។ ឥលូវនេះ ការផ្គត់ផ្គង់គ្រួសារគឺពឹងផ្អែកលើប្រាក់ខែប្ដីធ្វើជាប៉ូលីស។ ពេលថ្មីៗនេះពួកគាត់ បញ្ជូនកូន ៣នាក់ទៅសាលារៀន ចំណែកឯទារក និងកូនតូចអាយុ៤ឆ្នាំនៅផ្ទះ។ ម្ដាយចង់ឱ្យកូនប្រុសច្បង ឈប់រៀនដោយសារតែគាត់មិនអាចចំណាយលើការសិក្សារបស់កូនបាន ហើយគាត់ចង់ឱ្យកូនជួយថែទាំប្អូនៗ និងធ្វើការងារផ្ទះមួយចំនួន។

### ២.៣.១.៣ សកម្មភាពផ្សេងៗរបស់កុមារជាសិស្សនៅពេលទំនេរពីម៉ោងសិក្សា

**តារាង ២៤:** សកម្មភាពជួយការងារផ្ទះសិស្សនៅពេលទំនេរពីម៉ោងសិក្សា

| ការជួយការងារផ្ទះនៅពេលទំនេរពីម៉ោងសិក្សា | ប្រេកង់ | ភាគរយ |
|---|---|---|
| ធ្វើកិច្ចការងារផ្ទះ | ៧៧ | ៧៧% |
| ធ្វើការដើម្បីជួយរកចំណូលអោយគ្រួសារ | ៩ | ៩% |

| | | |
|---|---|---|
| មើលថែទាំប្អូន ជីដូនចាស់ និងក្មួយ | ៧ | ៧% |
| អត់ធ្វើអ្វីទេពីព្រោះនៅក្មេងនៅឡើយ | ៧ | ៧% |
| សរុប | ១០០ | ១០០% |

មួយភាគធំ ឬ៧៧% នៃសិស្ស បានជួយធ្វើការងារផ្ទះបន្ទាប់ពីត្រលប់មកពីរៀនវិញ។ កុមារ ឬវ័ជនមួយចំនួនជួយឪពុកម្តាយរបស់គេ ដើម្បីរកប្រាក់ចំណូល និងខ្លះទៀតនៅផ្ទះមើលថែទាំប្អូនៗ សាច់ញាតិ និងមនុស្សចាស់នៅក្នុងគ្រួសារ ។

# ជំពូក ៣
# សេចក្តីសង្ខេប សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៣.១ សេចក្តីសង្ខេប

### ៣.១.១ ទំហំគ្រួសារដែលឆ្លើយការសម្ភាសន៏

គ្រួសារភាគច្រើនជាទូទៅមានសមាជិកពី៥-៦នាក់ ហើយគ្រួសារនិមួយៗមានកូនជាមធ្យម៣-៤នាក់។ កូនស្ទើរតែទាំងអស់រស់នៅជាមួយឪពុកម្តាយ ហើយគ្រួសារភាគច្រើនដែលយើងបានសម្ភាសន៏រកស៊ីលក់ដូរបន្តិចបន្តួចនៅផ្ទះ ឬជាកសិកម្មជាលក្ខណៈគ្រួសារ។ គ្រួសារមួយភាគធំមានសមាជិកគ្រួសារពីរនាក់ជាអ្នករក ចំណូលឱ្យគ្រួសារ។ គ្រួសារនៅតំបន់ជនបទ រកចំណូលបានច្រើនជាងបើប្រៀបធៀបទៅនឹងគ្រួសារនៅតំបន់ប្រជុំជន និងតំបន់ដាច់ស្រយាល។ បើគិតជាមធ្យមគ្រួសារនីមួយៗមានកូនពី ២-៣នាក់បានចុះឈ្មោះចូលរៀន។

ប្រាក់ចំណាយប្រចាំថ្ងៃអោយកូនម្នាក់ទៅសាលារៀនគឺ២.៥០០រៀលនៅតំបន់ប្រជុំជន ១.៨០០រៀលនៅតំបន់ជនបទ និ១.៣០០រៀល នៅតំបន់ដាច់ស្រយាល។

### ៣.១.២ ការចំណាយរបស់ឪពុកម្តាយចំពោះការអប់រំ

**ចំណាយនៅដើមឆ្នាំ**

ចំណាយនៅដើមឆ្នាំមានដូចជាចំណាយលើ ឯកសណ្ឋានសិស្ស សម្ភារៈសិក្សា ការចុះឈ្មោះចូលរៀនមានចំនួនដល់៨៨.៥០០រៀលសំរាប់គ្រួសារនៅទីប្រជុំជន ចំណែកឯគ្រួសារនៅតំបន់ដាច់ស្រយាល និងតំបន់ជនបទមាន ៧៦.៧០០រៀល និង៨១.៦០០រៀល។ ប្រភេទចំណាយដើមឆ្នាំទាំងអស់នេះបង្កជាឧបសគ្គ ដល់ការចុះឈ្មោះចូលរៀននៃកុមារក្នុងគ្រួសារក្រីក្រ ។

**ចំណាយលើការសិក្សា**

ចំណាយលើការសិក្សារួមមាន ថ្លៃគ្រូបង្រៀន ការរៀនគួរបន្ថែម ក្រដាសមេរៀន និងក្រដាសប្រលង បានចាត់ជាចំណាយច្រើនទីពីរបន្ទាប់ពីចំណាយនៅដើមឆ្នាំនៃឪពុកម្តាយ។ ជាមធ្យមនៃចំណាយ លើការសិក្សាមាន ២០៩.៥០០រៀល។ មួយភាគធំនៃចំណាយលើការសិក្សា គឺជាចំណាយលើការរៀនគួរបន្ថែម។ ចំណាយជាមធ្យម សំរាប់រៀនគួរបន្ថែមគឺ ១៦៣.៦០០រៀលក្នុងមួយឆ្នាំ។

**ចំណាយប្រចាំថ្ងៃ**

ចំណាយប្រចាំថ្ងៃមានរាប់បញ្ចូល អាហារឬទំចំណី និងថ្លៃផ្ញើកង់/ម៉ូតូ។ ចំណាយប្រចាំថ្ងៃទាំងអស់នេះ បានក្លាយជាប្រភេទចំណាយច្រើនជាងគេដែលអ្នកផ្តល់សម្ភាសន៍បាន រាយការណ៍ប្រាប់យើង។ សិស្សម្នាក់អាច ចំណាយពី១៦៩.០០០រៀល ដល់២៨៩.០០០រៀល ក្នុងមួយឆ្នាំលើ ចំណាយប្រចាំថ្ងៃទាំងអស់នេះ។

**ចំណាយដទៃទៀត**

ចំណាយផ្សេងៗរួមមាន ប្រភេទចំណាយដូចជា សម្ភារៈសិក្សា និងសម្ភារៈថ្នាក់រៀន កាដូសំរាប់គ្រូ និង ចំណាយលើពិធីផ្សេងៗ។ គ្រួសារនៅតំបន់ប្រជុំជនចំណាយ២៣.៤០០រៀលលើចំណាយផ្សេងៗទៀត។ ចំណែក គ្រួសារនៅតំបន់ដាច់ស្រយាល និងតំបន់ជនបទចំណាយ១៤.២០០រៀល និង១៨.៩០០រៀល។

### ៣.១.៣ ផលប៉ះពាល់របស់ចំណាយក្រៅផ្លូវការទៅលើគ្រួសារ

ឪពុកម្តាយនៅនៅទីប្រជុំជនក្នុងខេត្តកំពង់ចាម ចំណាយជាមធ្យម៦១៣.៩០០រៀល ($១៥៣)ក្នុងមួយ ឆ្នាំដើម្បីបញ្ជូនកូនម្នាក់ឱ្យទៅរៀននៅសាលារដ្ឋ។ វាត្រូវជា១៥%នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារ។ គ្រួសារ នាំតំបន់ជនបទចំណាយ៦០០.២០០រៀល ($១៥០) សំរាប់កូនម្នាក់ដែលត្រូវជា១១% នៃប្រាក់ចំណូលប្រចាំឆ្នាំ។ ចំណែកឯគ្រួសារនៅតំបន់ដាច់ស្រយាលចំណាយ៤៤០.១០០រៀល($១១០)ត្រូវជា១០%នៃប្រាក់ចំណូលប្រចាំឆ្នាំ។ ដូច្នេះ ការបញ្ជូនកូនម្នាក់ឱ្យចុះឈ្មោះចូលរៀននៅ សាលាអប់រំថ្នាក់មូលដ្ឋាន ជាមធ្យមគេអាចចំណាយពី១១% ទៅ១៥% នៃប្រាក់ចំណូលរបស់គ្រួសារ។ ការចំណាយរបស់ពួកគេអាចកើនឡើងជាលំដាប់ប្រសិនបើគាត់បញ្ជូន កូនពីរនាក់ ឬច្រើនថែមទៀតឱ្យទៅរៀននៅសាលារដ្ឋ ។

**មូលហេតុដែលបណ្តាលអោយកុមារបោះបង់ការសិក្សា**

កុមារភាគច្រើនឈប់រៀនក៏ដោយសារតែហេតុផលសេដ្ឋកិច្ច។ ពួកគេនិយាយថាការមិនមានប្រាក់បង់ថ្លៃ រៀនគួរក្រៅម៉ោង និងការប្រលងធ្លាក់បានធ្វើឱ្យពួកគេបាក់ទឹកចិត្តក្នុងការបញ្ចប់ថ្នាក់អប់រំមូលដ្ឋាន។

**សកម្មភាពផ្សេងៗរបស់សិស្សដែលឈប់រៀន**

កុមារដែលបោះបង់ការសិក្សាបានជួយធ្វើការឳពុកម្តាយក្នុងការរកប្រាក់ចំណូលឱ្យគ្រួសារ ហើយខ្លះទៀតធ្វើការក្នុងរោងចក្រកាត់ដេរ និងផ្ទះសំណាក់ ។

**សកម្មភាពរបស់សិស្សនៅពេលទំនេរពីម៉ោងសិក្សា**

កុមារមួយភាគធំដែលស្ទង់មតិ គឺគេធ្វើកិច្ចការផ្ទះបន្ទាប់ពេលគេមកពីសាលាវិញ។ កុមារមួយចំនួនមានការងារក្រៅម៉ោងដើម្បីជួយរកចំណូលបន្ថែមឱ្យគ្រួសារ ។

## ៣.២ សេចក្តីសន្និដ្ឋាន

